Reçu le 2 Mai 1949.

INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ១

Septembre

ខែកញ្ញា ព. ស. ២៤៩២

ឆ្នាំសិក្សា ១៩៤៩-១៩៥០

# ព្រះរាជអាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

# គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ


វេយ្យាករណ៍ ........................................ ៥
ឧត្តមដ្ឋាន ........................................ ៧
មជ្ឈិមដ្ឋានទី ២ ........................................ ១១
— — ទី ១ ........................................ ១២
អាទិកដ្ឋានបង្រៀនពាក្យ - ភាសា ........................................ ១៣
បរិវច្ឆណដ្ឋាន ........................................ ១៩
មជ្ឈិមដ្ឋានទី ១ នព្វន្ត ........................................ ២៣
— — ១ ធរណីមាណសាស្ត្រ ........................................ ២៦
— — ២ រង្វាស់រង្វាល់ ........................................ ២៩
អាទិកដ្ឋាន - នព្វន្ត ........................................ ៣១
បរិវច្ឆណដ្ឋាន - រង្វាស់រង្វាល់ ........................................ ៣៥
កុមារដ្ឋាន - នព្វន្ត ........................................ ៣៩
— — រង្វាស់រង្វាល់ ........................................ ៤៣
អាទិកដ្ឋាន - វត្ថុស្វាធ្យាយន៍ ........................................ ៤៥
បរិវច្ឆណដ្ឋាន - វត្ថុស្វាធ្យាយន៍ ........................................ ៤៩
លោកនីតិ ........................................ ៥៣
មេសូត្ររត់មាត់ (គ្រប់ថ្នាក់) ........................................ ៥៧

# ពាក្យសរសេរត្រឹមត្រូវ

| | | |
|---|---|---|
| ថ្ងៃអាទិត្យ – | ពិនិត្យ – | មិនគិត |
| ត្រួតត្រា – | ខណ្ឌផ្ទី – | ព័ន្ធវិណ្ណ |
| លេបឡើង – | លិបបាត់ – | ពិបាក |
| ក្តារឆ្នួន – | ក្តារខៀន – | ពន្យល់ |
| បំនួន – | បំឬជំពោះ – | រណារអារ |
| បុណ្យ – | ម៉ែត្របត់ – | ផ្លាស់ប្តូរ |
| បាតក្រោម – | ប្រយ័ត្ន – | តុ ទូ |
| ទំព័រ – | នព្វន្ត – | សក់ជុះ |
| ដុសលាង – | លលាដ៍ក្បាល – | រលាបំណាង |
| ភ្លីញភ្លិត – | ភ្ជល់ភ្ជាប់គ្នា – | ភ្ជួរស្រែ |
| ភ្ជុំបិណ្ឌ – | ព្យួរសំពាយ – | ព្យាយាម |
| សម្បូណ៌សម្បត្តិ – | ទ្រព្យធន – | ផ្តុំគ្នា |
| ឆ្អឹងរឹង ៗ | | |

# វេយ្យាករណ៍

៙ ក្នុងវិធីអក្ខរៈ អ្នកសិក្សាត្រូវរៀនឱ្យស្គាល់ប្រាកដស្រៈនិងព្យញ្ជនៈ ព្រោះអក្ខរៈទាំងពីរយ៉ាងនេះជាប្រធាននៃវេយ្យាករណ៍ ។ ស្រៈមានពីរយ៉ាង គឺស្រៈពេញ និងស្រៈនិស្ស័យ ។ ស្រៈពេញទាំងឡាយ គឺ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ (១៥ តួ) ។ ស្រៈនិស្ស័យទាំងឡាយ គឺ ı ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ (២១ តួ) ។ ព្យញ្ជនៈទាំងឡាយ គឺ ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ដ្ត ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អំ(ំ) (៣៣ តួ)

សេចក្ដីចំណាំ.— អក្សរ ឮ គឺតួ ព និងជើងធ ។ ជើង ត តួចរឹល; ជើង ដ តួចតែ ១ ជំហៀង ។ ជើង ព បើផ្ញើនឹងអក្សរដទៃ ត្រូវដាក់តួ ព ខ្ទង់ឯង តែបើតួ ព តម្រួតខ្ទង់ឯង ត្រូវដាក់ជើងវ ។

៙ គេហៅស្រៈពេញ ព្រោះស្រៈទាំងនោះប្រើដូចតួព្យញ្ជនៈ ។ ស្រៈពេញតួគួរចងចាំហ្មត់ចត់ ព្រោះស្រៈទាំងនោះផ្លាស់រូបជាស្រៈនិស្ស័យ ដែលនាំឱ្យអ្នកសិក្សាងឿងឆ្ងល់រឿយ ៗ ក្នុងបទសមាស (សៈម៉ាស់) ដោយពាក្យដើមនឹងពាក្យផ្សំគ្នាជាសមាសរួចហើយសរសេរផ្សេងគ្នា ឧបមាដូចពាក្យ "ឧបករណ៍" ផ្សំជាបទសមាសជាមួយនឹងពាក្យ "យុទ្ធ" ផ្លាស់ទៅជា "យុទ្ធោបករណ៍": ផ្សំនឹងពាក្យ "នេសាទ" ផ្លាស់ជា "នេសាទោបករណ៍" ។ ពាក្យ = ភូមិន្ទ, សព្ហាហ, លោកេស្វរ, លោកុត្តរ, បរមាភិសេក, គុណោបការ, រយោធាធិបតី, ប្រជានុគ្រោះ..... សឹងជាពាក្យសមាសអំពីស្រៈពេញ ។

ស្រៈនិស្ស័យជាអក្ខរ អាស្រ័យនឹងតួព្យញ្ជនៈ នោះអ្នកសិក្សាប្រើជារឿយ ៗ តាមអធ្យាស្រ័យនៃខ្លួន ក្នុងពាក្យកើតពីស្រៈ ិ ី ឹ ឺ ។ នឹងប្រើដូច្នោះមិនមានការប្រសើរក្នុងភាសារបស់ជាតិឡើយ ។ បើពាក្យដែលយើងពុំសូវដែលប្រើញឹកញាប់ យើងត្រូវពិគ្រោះនឹងវចនានុក្រម ។ ស្រៈ ិ និង ី ក្នុងពាក្យដែលខ្ចីពីបាលី ឬ សំស្ក្រឹតឲ្យន័យខុសគ្នាស្រឡះ ។ ក្នុងពាក្យខ្មែរ ក៏មានទំនាស់អាន នឹងទំនាស់ធម្មជាតិរបស់ពាក្យដែរ ឧបមាដូចពាក្យ ពិត ពីត មិន មីន មឹន មឹឥ ពឹត.....។ ពាក្យកើតពីស្រៈ ឹ ប្រើជាដាច់ស្រេចនូវពាក្យដែលមានអក្សរ "គ" ជាប្រកប នឹងពាក្យក្លាយចេញពី "ឫ" ដូចពាក្យ "ម្រឹគ" ក្លាយពី ម្ឫគ ; ព្រឹក្ស ក្លាយពី វ្ឫក្ស ; ក្រឹត្យ ក្លាយពី ក្ឫត្យ..... ។ មានពាក្យខ្មែរសុទ្ធកើតពីស្រៈ ឹ ហើយមានអក្សរដទៃពី "គ" ជាប្រកប ដូចពាក្យ ដឹក, ឹក, ទឹក, ព្រលឹម, សឹក..... នោះយើងត្រូវពិគ្រោះសំឡេងស្រៈ ។

ព្យញ្ជនៈបែកជា ៥ វគ្គ និងអវគ្គ ១ ។ វគ្គនិមួយៗមានអក្សរ ៥ តួ ឯ-អវគ្គមានអក្សរ ៨ តួ ។ អក្សរនៅដើមវគ្គ ប្រើជាតួប្រកបនូវពាក្យខ្មែរ លើកតែអក្សរដើមវគ្គទី ៣; អក្សរនៅចន្លោះដើមនិងចុងវគ្គ ប្រើនូវពាក្យដែលមកពីបាលី ឬ ពីសំស្ក្រឹត; អក្សរនៅចុងវគ្គនិងអក្សរសេសវគ្គ ប្រើបានជាតួប្រ-កបនូវពាក្យខ្មែរ, បាលី ឬ សំស្ក្រឹត ។ មានពាក្យបាលីប្រែខ្លួនជាពាក្យខ្មែរខ្លះដែរ តែមានចំនួនតិចណាស់ ដូចពាក្យ បរិប, ទ្រូប, ធូប,..... ។ វគ្គឲ្យដឹងតួអក្សរដែលបែកទៅជាធាតុពាក្យ ឬ នាមក្រិត, កិរិយាក្រិត, ឬ ហៅកិតៈក៏បាន ។ ពាក្យដែលកើតឡើងពីអក្សរគ្មានតួពុំដែលមាននាមក្រិត កិរិយាក្រិតឡើយ ។ អក្សរនៅចុងវគ្គ និងអក្សរសេសវគ្គ សុទ្ធជាអក្សរពាលគឺគ្មានតួទាំងអស់ ។

វគ្គឲ្យដឹងពាក្យត្រូវតម្រួត ។ និងតម្រួតព្យាង្គត្រូវធ្វើតាមលំដាប់អក្សរក្នុងវគ្គ ។ ពាក្យតម្រួតក្នុងអក្សរសេសវគ្គពុំមានលំដាប់អក្សរឡើយ គេគ្រាន់តែដឹងថាព្យាង្គទាំងពីរនោះ បើញែកចេញដោយខ្លួន ព្យាង្គមួយៗ គ្មានសេចក្ដីប្រែ ។

វគ្គឲ្យដឹងសព្ទបម្រើអក្សរ មានចំនួនប៉ុន្មានក្នុងវគ្គជាអឃោសៈ ឬ ជាឃោសៈ និងឲ្យដឹងនូវអក្សរចុងវគ្គនិងអក្សរសេសវគ្គជាទ្វិសព្ទ; អក្សរ "ប" ជាត្រៃសព្ទ; អក្សរក្រៅពីនោះជាឯកសព្ទ; អក្សរ "ឡ" ជាឯកសព្ទដែរ ប៉ុន្តែជាសំបូរនឹង "ល" ជារឿយៗ ។

ពាក្យសួរ.— ១— វេយ្យាករណ៍ជាវិធីមានប្រយោជន៍ដើម្បីអ្វី? (និយាយត្រឹមត្រូវ, សរសេរត្រឹមត្រូវ)។ ២.— អក្ខរៈ ឬ អក្សរមានប៉ុន្មានយ៉ាង? (ស្រៈនឹងព្យញ្ជនៈ)។ ៣.— ស្រៈមានប៉ុន្មានយ៉ាង? (ស្រៈពេញនឹងស្រៈនិស្ស័យ)។ ៤.— ព្រោះអ្វីបានជាគេហៅស្រៈពេញ?— ស្រៈនិស្ស័យ? ។ ៥.— ស្រៈទាំងពីរយ៉ាងអាស្រ័យគ្នាដូចម្ដេច? ក្នុងបទអ្វី? (សមាស)។ ៦.— ចូរសូត្រតួព្យញ្ជនៈ ។ ៧.— ព្យញ្ជនៈមានប៉ុន្មានពួក?— ពួកមួយៗ មានអក្សរប៉ុន្មាន?— អក្សរអ្វីខ្លះដែលគ្មានពួក? ៨.— វគ្គមានប្រយោជន៍ដូចម្ដេច? ។ ៩.— អក្សរអ្វីខ្លះជាឃោសៈ ជាអឃោសៈ, ជាឯកសព្ទ, ជាទ្វិសព្ទ, ជាត្រៃសព្ទ? ។ ១០.— សម្លេងអក្សរជាអឃោសៈក្ដី ជាឃោសៈក្ដី មានប្រយោជន៍ដូចម្ដេច? (អានពាក្យ), ផ្ញើជើង ឬ ព្យញ្ជនៈផ្សំ; ដូចអានថា: ទស្សនា (ទស្សណា) ធរណី (ធរនី); ស្វ (ស្វ៉) ធ្វ (ធ-វ) ។

---

ឧត្តមដ្ឋាន

## រៀនមើល-សរសេរតាមសូត្រ

*សេចក្ដីខុសឆ្គងបន្តិចបន្តួច*

ចូរយើងកុំមើលងាយសេចក្ដីខុសឆ្គងបន្តិចបន្តួច ។ កំហុសនោះមិនជាអំពើធ្គាំធ្គង ដែលយូរទៅអាចធ្វើឲ្យវិនាសឡើយ ។ ប្រែះបាប់រហូតដល់ចុងដែក ដែលជ្រលក់ទឹកក្រឡៀយ៉ាងបំណាប់ ។ ខ្យងសោកបានធ្វើឲ្យប្រទេសហុល្លង់មានភ័យម្ដងហើយ ដោយ

ហោះឬលស់បន្ទាយទឹក ដែលជាការមាំបំផុតក្នុងលោក ។ សេចក្តីផ្គាំផ្គងសឹងជាដើមអាទិ៍នៃកំហុសឯរាប ។ អំពើពុតពាលនោះឯងដែរ ក៏ជាកូននៃសេចក្តីផ្គាំផ្គង ។ ចំណុចខ្មៅតូចកើតលើធ្មេញមួយវាមិនធ្វើទុក្ខអ្វីទេ តែបើអ្នកមិនឲ្យពេទ្យមើល ធ្មេញអ្នកនឹងខូចទាំងមូលពុំលែង ហើយបើអ្នកមិនឲ្យដកយកចេញ ធ្មេញឯទៀតនឹងខូចតាមគ្នាទាំងអស់ ។ សេចក្តីឆ្មើងក្លាយទៅជាអំពើផ្គាំផ្គង ។ អំពើផ្គាំផ្គងនោះមិនតូចតាចណាស់ទេ ព្រោះអំពើនោះលាក់ទុកកំហុស ។ កាលណាអ្នកធ្វើខុសអ្វីមួយ ហើយអ្នកមិនហ៊ានប្រាប់គេនោះតើនរណាលាក់ទុក គឺសេចក្តីឆ្មើងនោះឯង ។ កុហកជាបុត្រជិតដិតរបស់ក្តីឆ្មើង តែក្តីឆ្មើងនោះពុំមែនមានតែកូនមួយប៉ុណ្ណោះឡើយ ។ តាមដោយពិចារណា ខ្ញុំឃើញមានកូនពីរអាក្រក់ដូចគ្នា គឺឥស្សាមួយ នឹងឈ្នានិសមួយ ទាំងពីរនេះកើតទៅជាគំនុំគុំគួនដែលជាមេនៃគ្រូរទោស ។

ចូរអ្នកមានអធ្យាស្រ័យដល់កំហុសបន្តិចបន្តួចរបស់មិត្តសំឡាញ់អ្នក បើអ្នករំពឹងពុំបានតែកំហុសចំពោះខ្លួនអ្នកវិញ ចូរអ្នកប្រឹងជំនះលុះតែឈ្នះ ។

ពាក្យពន្យល់. — ឆ្គាំឆ្គង = មិនប្រព្រឹត្តកិច្ចប្រតិបត្តិត្រូវតាម ដូចជាពុំបានបើកមួកនឹងគ្រូជាដើម ។ — ប្រេះ = គឺ ស្នាមដែលកើតលើដែក ។ — ឆ្មើង = គឺ សេចក្ដីមើលងាយថាគេទាបជាងខ្លួន គឺខ្វះការគោរពតាមសភាវៈខ្ពស់ទាប ។ — ឥស្សា = ចិត្តខ្ញាញ់នឹងឃើញគេខ្ពស់លើសខ្លួន ។ — ឈ្នានិស = សេចក្ដីប្រឹងប្រែងធ្វើឲ្យគេវិនាសទៅ ។ — គរុទោស = ទោសធ្ងន់ គឺ ឧក្រិដ្ឋ; មជ្ឈិមទោស = ទោសយ៉ាងកណ្ដាល, លហុទោស = ទោសល្មើសបន្តិចបន្តួច ។ ទោសលោកសង្ឃហៅអាបត្តិ

ជម្ស្នានក្នុងបទវេយ្យាករណ៍. — សូមមើលជម្ស្នានក្នុងថ្នាក់មជ្ឈិមដ្ឋានទី ១ ទី ២ រួចបង្រៀនសិស្សការផ្លាស់ប្ដូរស្រៈពេញតួ ជាស្រៈនិស្ស័យក្នុងបទសមាស ដូចពាក្យ = លោកុត្តរ = លោក នឹង ឧត្តរ (លោក + ឧត្តរ = លោកុត្តរ) ។

---

## ចេតិយភ្នំពេញ

៦ ទស្សនាអំពីចម្ងាយមកទីក្រុងភ្នំពេញ យើងឃើញស្តូបមួយខ្ពស់ផុតទីព្រឹក្សា នឹងគេហដ្ឋានទាំងឡាយ ។ សញ្ញាញាំងយើងឲ្យដឹងថាហ្នឹងហើយជាក្រុងភ្នំពេញ ។ សេចក្តីទុកម្នេញក្នុងដំណើរក៏រសាយ បង្កើតសេចក្តីរីករាយចង់តែស្ទួតរូតឲ្យដល់ឆាប់ ។

ព្រះចេតិយរាងស្តុកស្តម្ភទំហំសមនឹងកំពស់ប្រហែល ៣០ ម៉ែត្រ ដោយប្រមាណ ។ តួអង្គនិភ្និភាយគាយស្រួលជាទង់ផ្កាត្រកួនគង់លើបល្ល័គ្គតាំងជាទ្រនាប់ខ្សាប់បីជាន់ ដ៏មានជ្រុងសរពើរស្ទូត្រ

ទំសង្កត់លើភ្នំតូចមួយ ។ ពីលើអង្គ កំពូលដោលទៅលើរៀវស្រួល ស្រួចទាល់ដាច់ របនាជាក្បាច់រូតកន្ធូតបំផុតនឹងត្រយ៉ូងបេកធ្វើនឹងឈើតាត្រាវ ។ តាំងពីតាទូតល្អូតលាវហូតដល់មកយើង ស្តូបនេះនៅតែឈរខ្ពស់ត្រដែត ដ៏មានទំហំធំសម្បើមមានឫទ្ធានុភាពគ្រប់ទីក្រុងភ្នំពេញ ។ ដោយទំនាយនៃស្រុកនឹងបានស្តូបនេះ ជាមង្គលអ្វីមួយ បណ្ដាលឲ្យរាជការរៀបតុបតែងក្នុងរាជ្យព្រះបាទនរោត្តមព្រមនឹងក្នុងសម័យលោកអធិបតីរាជការប្រូតិតុរាត់នាមហៅថាវៃរណ៍វីលយកស្ត្រីខ្មែរម្នាក់ឈ្មោះរឿងជាភរិយា ។ ព្រះវិហារកសាងឡើងដោយអិដ្ឋគ្រឿងឈើប្រក់ក្បឿង មានជណ្ដើរកាប់របនារូបនាគជាប្រកាន់ដៃ តាមរបៀបអង្គរ មានមាគ៌ាព័ទ្ធវិលវណ្ឌដល់កំពូលភ្នំ នឹងសួនច្បារនរុក្ខជាតិនានា មានទ្រុងចញ្ចឹមសត្វព្រៃគឺបក្សាបក្សីនរិន្ទវង្គសត្វម្រឹគាម្រឹគី ព្រះវិហារនឹងសួនច្បារសឹងជាបរិវាលំអព្រះស្តូបភ្នំពេញដ៏ជាគោលបារិក តែងបង្កើតសិរីសួស្តីមង្គលដល់ស្រុកខ្មែរនេះឯង ។

---

ពាក្យពន្យល់.— ទស្សនា = អានថា ទស្សណា = គឺការឃើញ — ស្តូប = ទីភេនធ្វើដោយអិដ្ឋឬថ្ម សំរាប់បញ្ចុះធាតុ, បាលី ហៅ សថូប ឬថូប ។ ចេតិយ = អានថា ចេដីយ ទីគោរព ។ គេហដ្ឋាន = ផ្ទះនានា ។— ម្រឹគា = សត្វជើងបួន; ម្រឹគី = ញី ។

## មធ្យមដ្ឋានទី ២

## រៀនមើល-សរសេរតាមសូត្រ

### ឆ្មាស្រុកនឹងឋាបពូក

*រឿងសម្រាំងទំព័រ ១៧៧*

**ពាក្យពន្យល់.—** និវត្ត = អានថា និវត់ត គឺងាកចិត្ត ។

**ពាក្យសួរ—** រឿងនេះបានគតិដូចដំណើរអ្វី? (ដំណើរដូចអ្នករាជការដែលស្លូតប្រាក់រាជការ ព្រោះធ្លាប់ចាយលេងសើច លុះទាល់ក៏កើតចិត្តអាក្រក់ឡើង ។ ១ ទៀតជាជម្ងឺគ្មានថាអ្វីៗជាសត្រូវកុំឲ្យទុកចិត្តពេក) ។

**ជម្ងឺគ្មានក្នុងបទវេយ្យាករណ៍.—** សូមមើលពាក្យជម្ងឺគ្មានក្នុងថ្នាក់មធ្យមដ្ឋានទី ១ ហើយសូមប្រាប់សិស្ស អំពីប្រយោជន៍វគ្គដូចម្ដេច, សម្លេងអក្សរប្រយោជន៍ដូចម្ដេច, សិថិលនឹងធនិតប្រយោជន៍ដូចម្ដេច ។

### ស្រីពីរនាក់ដណ្ដើមកូនគ្នា

*រឿងសម្រាំង ទំព័រ ១៤៩*

**ពាក្យសួរ —** អ្នកយល់ឃើញនូវសេចក្ដីវិនិច្ឆ័យព្រះរាជាដូច ម្ដេច ?— សេចក្ដីត្រង់ណាដែលជាផ្លូវសុចរិត ?

**សេចក្ដីបំណាំ.—** ស្រីក្លូនស្លាប់ (នាម) ព្រះស្វែងលែងកូន (នាម)

## មធ្យមដ្ឋានទី ១

## រៀនមើល-សរសេរតាមសូត្រ

### ពិគ្រោះពេត

គ្រូពេទ្យផ្ទៀងស្ដាប់សូរដើមទ្រូង ស្ទាបខ្នងពិនិត្យមើលតាងម៉ាត់ ដោយប្រុងប្រយ័ត្ន តោះម្ដងៗ គ្រូពេទ្យងក់ក្បាលដូចជាសង្កេតឃើញត្រូវគំនិតដែលគ្រូពេទ្យបានយល់ ។ លុះពិនិត្យរួចហើយ គ្រូពេទ្យគ្របនាងម៉ាត់ ទាញខ្នើយតំរង់នៅក្រោមក្បាល ដោយដៃស្ទាត់ជំនាញនឹងថ្នាក់ថ្នម រួចហែកក្រដាសសមួយសន្លឹក ពីក្នុងកញ្ចប់ក៏កត់ពុំមានល្អៀងសេចក្ដីបង្គាប់ បញ្ញត្តិឲ្យនៅស្ងៀមឲ្យយកកម្លាំងនឹងឲ្យៗបំណីដែលល្អបរិភោគ ។

---

**ពាក្យសួរ** — នឹងពិនិត្យពេត គ្រូពេទ្យធ្វើដូចម្ដេច? ពិនិត្យរួចហើយ គ្រូពេទ្យធ្វើអ្វីទៀត? អ្នកស្គាល់ថ្នាំអ្វី ដែលរំងាប់គ្រុន, រំងាប់ឈឺក្បាល? — គេត្រូវតមកុំស៊ីផឹកអ្វីក្នុងសម័យមានពេតអសន្ន? បេស្ដ, ចុះក្អួត, អុតជាជម្ងឺដូចម្ដេច?

**ជម្ងឺនានាក្នុងបទវេយ្យាករណ៍.** — នៅថ្នាក់នេះ សូមលោកគ្រូបង្ហាត់ឃាំងមាំមួន = ស្រៈ, ព្យញ្ជនៈ; ស្រៈនិស្ស័យ ទាំងអាន ទាំងសរសេរ, ស្រៈពេញតួ ឬស្រៈពេញ; ព្យញ្ជនៈ ត្រូវឲ្យចេះស្គាល់រូបអក្សរ រួចត្រូវដឹងវគ្គ សេសវគ្គ; ពួកអក្សរឃោសៈ នឹងពួកអឃោសៈ សិថិល ធនិត ព្រោះការថ្មើកក្នុងព្យញ្ជនៈសឹងជាប្រធាននៃបទវេយ្យាករណ៍ខ្មែរ ។

## អាទិកដ្ឋាន

## បង្រៀនពាក្យនិងភាសា

ពាក្យនឹងភាសា គឺជាវិជ្ជាមួយយ៉ាងវិសេស ដែលបំបែកទៅវិជ្ជាឯទៀត ដូចជាវិជ្ជាបង្រៀនមើល-សរសេរតាមសូត្រ ។ល។ ឯបង្រៀនពាក្យមុនដំបូង ត្រូវបង្រៀនពាក្យណាដែលងាយៗសិន រួចសឹមបង្រៀនពាក្យពិបាកជាខាងក្រោយ ។

បើបង្រៀន នាម ត្រូវឲ្យមានរបស់ដែលជា នាម មកបង្ហាញ-ពន្យល់ បើគ្មានរបស់នោះទេ ត្រូវគូររូបបង្ហាញសិស្ស បើមានរូបស្រាប់ឲ្យបង្អុលបង្ហាញផង ។ បង្រៀន គុណនាម ត្រូវប្រៀបប្រដូចរបស់នោះឲ្យឃើញថា តូចធំ វែងខ្លី សខ្មៅ ល្អអាក្រក់ ។ល។ បង្រៀន កិរិយាសព្ទ គឺត្រូវឲ្យសិស្សធ្វើទំនងតាមកិរិយារបស់នោះ ដូចជាបង្គាប់សិស្ស ឲ្យក្រោក ឲ្យដើរ ឲ្យឈរ ឲ្យជូត ឲ្យបិត ។

## អាទិត្យទី ១ – បង្រៀនពាក្យ

### ១ – អំពីសាលារៀន

នាម.– ឆ្នាំសិក្សា ពេលចូលរៀន ពេលសំរាក សាលាសិក្សាវត្ត សាលាបឋមវិជ្ជានៅភូមិ សាលាបំពេញវិជ្ជា សាលាឧត្តមវិជ្ជា សញ្ញាប័ត្រ ។

គុណនាម – ថ្មី ចាស់ យូរ ឆាប់ ជិត ឆ្ងាយ ឧស្សាហ៍ ខ្ជិល ។

កិរិយាសព្ទ.– សុំចុះឈ្មោះ ចូលរៀន រៀនបំពេញវិជ្ជា ឈប់សំរាក ឈប់រៀន ឡើងថ្នាក់ ប្រឡង បានសញ្ញាប័ត្រ ។

## របៀបបង្រៀនពាក្យនិងភាសា

១– គ្រូសរសេរពាក្យនៅក្ដារខៀនម្ដងមួយៗ តាមសេចក្ដីសួរដោយ ហើយពន្យល់ឲ្យច្បាស់លាស់ កែសំដីសិស្សឲ្យនិយាយឲ្យច្បាស់ ។

គ្រូត្រូវមើលពាក្យមុន រួចសឹមឲ្យសិស្សមើលច្រើនគ្នាតទៅ ។

សួរសាពាក្យនេះឡើងវិញ ក្រែងសិស្សមិនយល់ច្បាស់ប្រាកដ ។

ឲ្យសិស្សចម្លងពាក្យនេះដាក់ក្នុងសៀវភៅ ។

ហាត់ភាសា.– ក្នុងមួយឆ្នាំសិក្សា កូនសិស្សរៀនប៉ុន្មានខែ? ឈប់សំរាកប៉ុន្មានខែ? នៅពេលណាដែលគេចូលរៀនជាថ្មី? សាលាដែលអ្នករៀនឈ្មោះសាលាអ្វី? (សាលាសិក្សាវត្ត ឬសាលាបឋមវិជ្ជានៅភូមិ ។ល។)

កូនសិស្សត្រូវធ្វើដូចម្ដេចឲ្យបានឡើងថ្នាក់ – ឲ្យបានប្រឡងជាប់លេខ? ។

ហាត់សរសេរ.– ឲ្យតែងសេចក្ដីខ្លីៗ ជាឃ្លា ឬឲ្យសិស្សបំពេញសេចក្ដីនៅកន្លែងចន្លោះពងក្រែ ដូចគំរូខាងក្រោមនេះ ក្នុងមួយឆ្នាំសិក្សា. ..(កូនសិស្ស)មករៀន... ....(៩ ខែ) ឈប់សំរាក......(៣ ខែ) ។ ខ្ញុំរៀននៅសាលា.......(សិក្សាវត្ត ឬបឋមវិជ្ជានៅភូមិ ។ល។) ។ ខ្ញុំត្រូវ.......(ខំស្វាហាប់រៀនសូត្រ) ដើម្បីឲ្យបានឡើងថ្នាក់ ឬប្រឡងជាប់នៅ.......(ពេលដាច់ឆ្នាំ) ។

# ២– កូនសិស្សឧស្សាហ៍រៀនសូត្រ

សៀវភៅវិជ្ជាខេមរភាសាបវេច្ចណដ្ឋាន ទំព័រ ២៥ មេរៀនទី ១៧ សូមរកពាក្យខ្វះក្នុងមេរៀននេះ – គិត = ត្រូវសរសេរជា គិត មិន = ជាមិន ។ ត្រឹម = ជាត្រឹម ។

ណាម.– សព្ទគតិព្យាយាម ប្រាជ្ញា ចំណេះវិជ្ជា គ្រូឈ្មោះ ស្មាតី នាម៉ឺន កស្ត្រ អ្នកមាន អ្នកក្រលំបាក មនុស្សចេះដឹង មនុស្សល្ងង់ខ្លៅ កូនសិស្សកំជិល ឧស្សាហ៍ ។

គុណនាម.– ចេះដឹង ល្ងង់ខ្លៅ ខ្ជិល ឧស្សាហ៍ ចំរើន អាប់ឱន ក្រលំបាក ទាបថោក ។

កិរិយាសព្ទ.– យកចិត្តទុកដាក់ ប្រុងប្រយ័ត្ន ស្ដាប់បង្គាប់ គោរព ធ្វើនាម៉ឺន រកស៊ី យកដំកប់តាម ។

ហាត់ភាសា.– អ្នកត្រូវធ្វើដូចម្ដេចឲ្យបានចេះដឹង? អ្នកស្រឡាញ់ចំណេះវិជ្ជាឬទេ? ហេតុអ្វី? មនុស្សចេះដឹងយ៉ាងដូចម្ដេច? ចុះមនុស្សល្ងង់ខ្លៅយ៉ាងណាវិញ? ដល់អ្នកធំឡើងអ្នកចង់ធ្វើអ្វី? (ចង់ធ្វើនាម៉ឺនឬរកស៊ី) ។ ហេតុអ្វី? ។

បើមេរៀននេះមិនគ្រប់គ្រាន់ទេ សូមលោកគ្រូបង្រៀនជ្រើសរើសសេចក្ដីឯទៀតយកមកបង្រៀន ពាក្យ ហាត់ភាសា-ការហាត់សរសេរ ថែមទៀតចុះ តែសេចក្ដីនោះឲ្យត្រូវគ្នាទៅលើ "សាលារៀន-កូនសិស្ស-ប្រដាប់ប្រដារបស់សិស្ស" តាមកំណត់ថែកវិជ្ជាបង្រៀនក្នុងខែទី១ ។

# បង្រៀនមើល

១— ពីព្រោះអ្វីបានជាខ្ញុំទៅសាលារៀន សៀវភៅវិជ្ជាខេមរភាសា បវេច្ចណដ្ឋាន ទំព័រ ៤ មេរៀនទី ៣ ។ ពន្យល់ពាក្យពិបាក — មិត្តសំឡាញ់ ពតិមាន ផលព្រះធរណី ទូន្មាន លុះ ដោយគន្ធធម៌ ។

២— សេចក្តីព្យាយាមនឹងបានសំរេចដូចប្រាថ្នា សៀវភៅវិជ្ជាខេមរភាសា បដិញ្ញាណដ្ឋាន ទំព័រ ៨២ មេរៀនទី ៥៥ ។ ពន្យល់ពាក្យពិបាក — សញ្ញាប័ត្រឧត្តមវិជ្ជា- សា ាក បឋមវិជ្ជាបាក់ឌ ខ្វះ ដុតចំគីរៀន សេចក្តីព្យាយាម ។

## របៀបបង្រៀនមើល

១— ឲ្យចម្លងសូត្រនេះមុនម៉ោងនៅក្តារខៀនបញ្ឈរ ដោយអក្សរផ្ចិតផ្ចង់ បើជាសិស្សនោះគ្មានសៀវភៅគ្រប់គ្រាន់ទេ ។

គ្រូត្រូវមើលសូត្រនេះមុនឲ្យសិស្សស្តាប់ ជាមួយ ៗ ឲ្យច្បាស់ ៗ ពាក្យ ឬ តួអក្សរ ។

គ្រូមើលសូត្រនេះឲ្យសិស្សមើលតាម ពីរឬបីនាក់ម្តង ឬឲ្យមើលព្រមគ្នាទាំងអស់ក៏បាន រួចបង្គាប់ឲ្យសិស្សម្នាក់មើល ឲ្យថាខ្យល់អក្សរឲ្យត្រឹមត្រូវ ។

ពន្យល់ពាក្យពិបាកដែលមាននៅក្នុងសូត្រ ។

ឲ្យហៅសិស្សផ្លាស់គ្នាមកមើលសូត្រនេះ កុំឲ្យហៅសិស្សរៀងគ្នាតាមតុ។ គ្រូកែពាក្យសំដីណាដែលសិស្សថាមិនច្បាស់ ។

# សរសេរតាមសូត្រ

សូមលោកគ្រូជ្រើសរើសសេចក្ដីណា ដែលបានបង្រៀន ក្នុងបង្រៀនពាក្យ ហាត់ភាសា-បង្រៀនមើល យកមកបង្រៀនដាក់អក្សរត្រឹមត្រូវផងចុះ តែមិនត្រូវយកពាក្យពិបាកណាមួយដែលសិស្សមិនទាន់បានឃើញ បានស្គាល់ មកឲ្យសរសេរតាមគ្រូជាទេ ។

## អំពីបង្រៀនដាក់អក្សរត្រឹមត្រូវតាមគ្រូជា

១ – មុនដំបូងត្រូវមើលសូត្រឲ្យសិស្សស្ដាប់ រួចសរសេរពាក្យពិបាកជាចំណាំនៅក្ដារខៀន ហើយពន្យល់ពាក្យនោះផង ។

ឲ្យសិស្សសរសេរពាក្យនោះនៅក្នុងក្ដារខៀនជាច្រើនដង ហើយឲ្យមើលប្រកបថា ពាក្យនោះ រួចហើយលុបចេញ ។

ត្រូវលុបពាក្យដែលសរសេរនៅក្ដារខៀនចោលចេញ ប្រយោជន៍ធ្វើបែបនេះ ដើម្បីឲ្យសិស្សឃើញពាក្យនោះត្រឹមត្រូវ :

ក )– ឲ្យសិស្សចំណាំដោយភ្នែកបានឃើញ ។

ខ )– ឲ្យសិស្សសរសេរពាក្យនោះច្រើនដង ដើម្បីឲ្យចំណាំដោយដៃបានគូស បានសរសេរ ។

ហៅសូត្រឲ្យសិស្សសរសេរតាម ថាឲ្យមួយ ៗ ហើយច្បាស់លាស់ផង គ្រូដើរក្រោយខ្នងសិស្ស ដើម្បីសំគាល់មើលថា សិស្សនេះសរសេរខុសច្រើន សិស្សនោះសរសេរត្រូវច្រើន ។

ត្រូវសរសេរកែសូត្រនេះ នៅក្ដារខៀនម្ដងមួយ ឃ្លា ៗ ឲ្យសិស្សកែសៀវភៅ តាមពាក្យណាដែលគាត់សរសេរខុស ឲ្យសិស្សគូសបន្ទាត់ពីក្រោម ឲ្យសរសេរពាក្យត្រូវពីលើពាក្យខុស ឬនៅខាងដើមបន្ទាត់ ហើយឲ្យដាក់ចំនួនខុសប៉ុន្មានផង ។

គ្រូត្រូវមើលកែដាក់ពិន្ទុឲ្យសិស្សផង ។

ឲ្យសិស្សសរសេរពាក្យដែលខុស (ពាក្យខុសមួយម៉ាត់ឲ្យសរសេរមួយបន្ទាត់) ។

## អក្សរផ្ចង់

យើងត្រូវជ្រើសរើសតួអក្សរដែលមានបែបភាពប្រហាក់ៗ គ្នា មកដាក់ឲ្យសិស្សហាត់សរសេរ ដូចខាងក្រោមនេះ —

ក ភ គ ត ឥ ក្ដៀ

ក កា កី កូ កួ កើ កៀ កែ កោ កៅ កុំ កំ កាំ

កុំកោកកាក កើតក្ដីក្ដាំ កុំភូតភគេ

(ឲ្យសរសេរអក្សរធំ ១ បន្ទាត់ កណ្ដាល ១ បន្ទាត់ តូច ១ បន្ទាត់)

### របៀបបង្រៀនអក្សរផ្ចង់

១ – គ្រូសរសេរអក្សរជាគំរូដាក់ឲ្យសិស្សមើលនៅក្ដារខៀនចញ្ជរ ។ បង្ហាញតួអក្សរដែលគេត្រូវចាប់សរសេរ ។

បរិវេច្ឆណដ្ឋាន

# បង្រៀនមើល

ក្នុងខែដំបូងនេះ សិស្សនៅថ្នាក់កុមារដ្ឋាន ទើបនឹងបានឡើងមកថ្នាក់បរិវេច្ឆណដ្ឋាន ឯរបៀបរៀនមើលនឹងហាត់និយាយនោះពុំទាន់បានស្ទាត់ហ្មត់ចត់តាមឃ្លាល្បះគ្រប់ៗគ្នានៅឡើយទេ ហេតុនេះសូមលៃលកតាមចំណេះវិជ្ជាកំឡាំងប្រាជ្ញាស្មារតីសិស្សនោះចុះ ។

## អាទិត្យទី ១ — សាលារៀនល្អ

*សៀវភៅវិជ្ជាខេមរភាសាបរិវេច្ឆណដ្ឋាន ទំព័រទី ១*

ពាក្យពន្យល់ — សាលា = ពាក្យបាឡីប្រែថា: រោង ឬ មន្ទីរសំរាប់ធ្វើបុណ្យ ឬសិក្សាវិជ្ជាគ្រប់យ៉ាង ។ ទ្វារ = ពាក្យបាឡីប្រែថា: ផ្លូវចេញចូល សំរាប់បើក-បិទបាន ។ សិស្ស = ពាក្យបាឡីប្រែថា: អ្នករៀន (ឈ្មោះតែរៀនវិជ្ជាអ្វីក៏ដោយ អ្នករៀនទុកជាសិស្ស) តិរច្ឆាន = ពាក្យបាឡីប្រែថា: សត្វទៅដោយទទឹង (ពួកសត្វជើង ៤ មានគោ-ក្របីជាដើម ពួកសត្វជើង ២ មានមាន់-ទាជាដើម) ។ សប្បាយ = ពាក្យបាឡីប្រែថា: ស្រួល (ដេក-ដើរ-ឈរ-អង្គុយ) ស្រួល ។ សុចរិត = ពាក្យបាឡីប្រែថា: ចរិតៈ ប្រព្រឹត្ត, សុល្អ ភ្ជាប់គ្នាថា: ប្រព្រឹត្តល្អ ឬប្រព្រឹត្តត្រឹមត្រូវ ។

ពាក្យសួរ.— រឿងនេះគេនិយាយអំពីអ្វី ។ ហេតុដូចម្តេចបានជាគេហៅថាសាលារៀន ។ គេសង់នឹងអ្វីសាលានោះ ។ មានរបស់អ្វីខ្លះនៅក្នុងសាលារៀន ។ នៅក្នុងសាលានិមួយៗ មានកូនសិស្សច្រើនឬតិច ។ ហេតុអ្វីបានជាអ្នកមករៀន ។

ឯការហាត់និយាយ សូមបង្គាប់សិស្សឲ្យឆ្លើយតបមកលោកគ្រូវិញថាៈ ខ្ញុំបាទ ពីព្រោះមានសិស្សខ្លះឆ្លើយថាតែខ្ញុំទេ មិនថាខ្ញុំបាទ បើឆ្លើយតបទៅនឹងអ្នកធំជាន់ខ្ពស់ត្រូវថាៈ ខ្ញុំប្របាទ ឬ ខ្ញុំប្របាទម្ចាស់ថែមទៀតផង ។

បង្ហាត់បំពេញពាក្យ.— ដូចមានរបៀបតទៅនេះ ឥដ្ឋ-ទ្វារ-កណ្តាល-តុ-ជើងម៉ា-ខ្ធំ ៗ-ចូលចិត្ត-វិជ្ជា ។

សាលារៀននោះសង់នឹង·····ប្រកក្បឿង···មាន·····ធំទូលាយ បង្អួចលាបពណ៌បៃតងខ្ចី សង់នៅ···ទីដីទួលរាបស្មើ ។ នៅក្នុងសាលារៀនមានរបស់ច្រើនគឺៈ··· នឹង·····នឹង····សំរាប់ដាក់សៀវភៅលោកគ្រូ ។ ខ្ញុំបាទ·····មកសាលារៀនណាស់ ពីព្រោះចង់បានចំណេះ···គ្រប់យ៉ាង ។

---

## បង្រៀនពាក្យ-អំពីប្រដាប់ប្រដារបស់កូនសិស្ស

នាម.— *សៀវភៅមើល-សៀវភៅសរសេរ-ដងប៉ាកកា-ស្លាបប៉ាកកា-ដបទឹកខ្មៅ-បន្ទាត់-ខ្មៅដៃ-ក្រដាសជូត-ជ័រលុប-ដីស-ក្តារខៀន ។*

គុណនាម.— *ក្រាស-ស្តើង-ធ្ងន់-ស្រាល-ស្រួច-ទាល-វែង-ខ្លី-ទន់-រឹង-ផុយ-ស្អិត-ធំ-តូច ។*

កិរិយាសព្ទ.— *មើល-សរសេរ-គូរ-ជូត-លុប-បើក-បិទ ។*

*ឯរបៀបបង្រៀនពាក្យដូចខាងលើនេះ ជាការស្រួលណាស់ ពីព្រោះរបស់ទាំងនោះមាននៅក្នុងថ្នាក់រៀនស្រាប់ សូមលោកគ្រូបង្ហាត់និយាយនាមភ្ជាប់នឹងគុណនាមហើយនឹងកិរិយាសព្ទ ដូចឧទាហរណ៍តទៅនេះ ។*

ការហាត់ភាសាភ្ជាប់.— សៀវភៅមើលរបស់អ្នកក្រាសឬស្តើង ។ សៀវភៅមើលរបស់ខ្ញុំបាទក្រាស, ក្រាសជាគុណនាម សៀវភៅមើលជានាម ។ ដងប៉ាកការបស់អ្នកធ្ងន់ឬស្រាល ។ ដងប៉ាកការបស់ខ្ញុំបាទស្រាល ។ ស្រាលជាគុណនាម ដងប៉ាកកាជានាម ។ល។

បែបម្យ៉ាងទៀតៈ.— ដបទឹកខ្មៅតូច, តូចជាគុណនាម ។ បន្ទាត់វែង, វែងជាគុណនាម ។ល។

កូនសិស្សលុបក្ដារខៀន, លុបជាកិរិយាសព្ទ ។ កូនសិស្សមើលសៀវភៅ, មើលជាកិរិយាសព្ទ ។ល។

ឯភាសាខ្មែរត្រូវការនិយាយឬសរសេរ ត្រូវដាក់នាម រួចដាក់គុណនាម ជាលំដាប់គ្នាដូចឧទាហរណ៍ថា: មនុស្សចាស់, ចាស់ជាគុណនាម ។ មនុស្សក្មេង, ក្មេងជាគុណនាម ។ ដំរីកាច, កាចជាគុណនាម ។ សេះស្គត, ស្គតជាគុណនាម ។ល។

បំណែកកិរិយាសព្ទវិញ ជួនណានៅខាងដើម ជួនណានៅខាងចុង ជួនណានៅកណ្ដាល ដូចឧទាហរណ៍ថា: ស៊ីបាយហើយ-បរិភោគហើយ-ផឹកទឹកហើយ-ស៊ី-បរិភោគ-ផឹក ជាកិរិយាសព្ទនៅខាងដើម ។ ឆ្កែខាំ-ឃ្មុំទិច-ពស់ចឹក ។ ខាំ-ទិច-ចឹក ជាកិរិយាសព្ទនៅខាងចុង ។ កូនសិស្សទៅសាលារៀន-លោកគ្រូអង្គុយលើកៅអី-កូនសិស្សកំពុងរៀនអក្សរ ។ ទៅ-អង្គុយ-រៀន ជាកិរិយាសព្ទនៅកណ្ដាល ។

# តែងសេចក្ដី

*បំពេញពាក្យខាងក្រោមនេះ*

## សរសេរតែងជាឃ្លាៈ អំពីសាលារៀនល្អ

*សាលារៀនខ្ញុំបែក ..... ជញ្ជាំងធ្វើអំពី ..... ហើយមានទ្វារ ...... បង្អួច ..... កាលណាខ្ញុំចូលទៅខ្ញុំឃើញ ........ ជប់ នៅខាងមុខតុសិស្សគឺ ..... នៅខាងក្រោយតុលោកគ្រូមាន ... ។*

*សាលារៀនខ្ញុំស្អាតណាស់ ព្រោះលោកគ្រូនិងសិស្សខំថែទាំរាល់ថ្ងៃ ។*

## សរសេរតាមសូត្រ

*ឯរបៀបសរសេរតាមសូត្រនៅថ្នាក់បវិវច្ចណដ្ឋាននេះ សូមឲ្យលោកគ្រូស្រង់ពាក្យពិបាក ៗ ឲ្យច្រើនមកបញ្ជាក់ជាមុន គឺឲ្យមើលសរសេរ ហើយទើបសូត្រសេចក្ដីដែលឲ្យសិស្សសរសេរតាមនោះបានមួយចប់ ។*

## ពីព្រោះហេតុអ្វីបានជាខ្ញុំទៅសាលារៀន

*សៀវភៅវិជ្ជាខេមរភាសាបវិវច្ចណដ្ឋានទំព័រ ៤*

របៀបបញ្ជាក់.— *ត្រូវឲ្យសិស្សគ្រប់គ្នាប្រុងចាំសរសេរនៅក្ដារជ្នួនតាមពាក្យគ្រូថា ទោះបីពាក្យ ១ ព្យាង្គក្ដី ឬពីរ - បីព្យាង្គក្ដី រួចហើយលើកបង្ហាញលោកគ្រូដោយរួសរាន់ បើសិស្សណាសរសេរខុសឲ្យសិស្សនោះកែខ្លួនភ្លាម ។*

*បើគ្មានក្ដារជ្នួនគ្រប់គ្នាទេ ឲ្យសិស្សម្នាក់ទៅសរសេរនៅក្ដារខៀន ។*

មធ្យមដ្ឋានទី ១

# នព្វន្ត

*កម្មវិធីនេះត្រូវរៀនចំនួនពី ១ ដល់ ១០០*

នឹងធ្វើឲ្យសិស្សឃើញជាក់ស្តែង ក្នុងការបង្រៀននព្វន្តនោះ សុំគ្រូបង្គាប់សិស្សឲ្យរកចំរៀកឫស្សីម្នាក់ ១០ ហើយចងជាបាច់ដប់ៗ រួចដាក់បាច់ដប់ដោយដប់ បាច់រាយដោយរាយ ។

*អាទិត្យទី១–* បំនួនពី ១ ដល់ ៥០

១– បង្ហាញលេខសញ្ញាពី ១ ដល់ ៩ ហើយនឹងសូន្យ (០) ហៅថាលេខរាយ ។ បង្ហាញខ្ទង់រាយនឹងខ្ទង់ដប់ ។

បំនួនពី ១០ ដល់ ៥០ ត្រូវយកចំរៀកឫស្សីដាក់ជាពីពួកក្នុងបំពង់ពីរផ្សេងគ្នា គឺពួកខ្ទង់ដប់នឹងពួកខ្ទង់រាយ ។

ឧបមាដូចរៀបចំនួន ១៣ ត្រូវយកចំរៀកឫស្សី ១ ដែលចំនួនខ្ទង់ដប់ដាក់ក្នុងបំពង់ ១ ហើយយកចំរៀកឫស្សីរាយ ៣ ដាក់ក្នុងបំពង់ ១ ទៀត រួចបង្គាប់ឲ្យមើលហើយថា

ខ្ទង់ដប់ ខ្ទង់រាយ

ចំនួននេះ(១៣)គ្រូសរសេរចំនួន១៣នៅក្ដារខៀនបញ្ឈរ ។ គ្រូយក បំរៀកឬស្សីវាយរ ៤ ទៀត មកដាក់ក្នុងបំពង់ដែលមានបំនួនមុននោះ បានជាវាយ ៧ ឲ្យសិស្សមើលហើយថា (១៧) គ្រូត្រាទុកបំនួន១៧ នេះ នៅក្ដារខៀនទៀត ។ល។ គ្រូធ្វើយ៉ាងដូច្នេះរហូតដល់ ៥០ ។

ឯបំនួន ១០ ។ ២០ ។ ៣០ ។ ៤០ នឹង ៥០ គឺ ១០ មួយដង - ១០ ពីរដង - ១០ បីដង - ១០ បួនដង - ១០ ប្រាំដង ត្រូវបញ្ជាក់សិស្សឲ្យយល់ប្រាកដថា មានបំរៀកឬស្សីតែនៅបំពង់ខាងខ្នង់ដប់ ឯក្នុងបំពង់ខ្នង់រាយឥតមានអ្វីសោះ គឺ សូន្យ (០) រួចសរសេរបំនួនទាំងនេះ នៅក្ដារខៀនទៀត ។ លុះបង្រៀនបំនួនចប់ហើយ ត្រូវឲ្យសិស្សមើលបំនួនដែលគ្រូបានសរសេរទុកនៅក្ដារខៀនបញ្ឈរនោះ ។

២– ឲ្យរាប់បន្ថែម ២ - ២ ទៅលើបំនួន ១ រហូតដល់ ៤៩ រួចរាប់បន្ថយ ២ - ២ ពី ៤៩ សាបុះមកដល់ ១វិញ ។

ឲ្យរាប់បន្ថែម ៣ - ៣ ទៅលើបំនួន ១ រហូតដល់ ៤៩ រួចរាប់បន្ថយ ៣ - ៣ ពី ៤៩ បុះមកដល់ ១វិញ ។

៣ – វិធីហាតគិតមាត់ទទេ ។– ម្ដាយចៅកៅមានប្រាក់២៥រៀល គាត់លក់បន្ថែបាន ៧ រៀលទៀត តើគាត់មានប្រាក់ទាំងអស់ប៉ុន្មាន។

ឪពុកបៅសនមានស្រូវ ៥០ ថាំង គាត់លក់ម្តង ៨ ថាំង លក់ម្តងទៀត ១២ ថាំង តើគាត់នៅសល់ស្រូវប៉ុន្មានថាំង ។

សៀវភៅខ្ញុំមាន ៣២ ទំព័រ ខ្ញុំសរសេរអស់ ១០ ទំព័រហើយ តើនៅប៉ុន្មានទំព័រទៀតពុំទាន់សរសេរ ។ល។

៥– បង្រៀនធ្វើលេខបូកលេខសងតិចត្រាទុក

សូមគ្រូបង្រៀនពាក្យថាៈ ថែមនឹង-ផ្សំនឹង-បូកនឹង-ដកចេញ ហូតចេញ យកចេញ ។

នឹងធ្វើឲ្យឃើញជាក់ស្តែងក្នុងការបង្រៀនធ្វើលេខបូកឬសង នោះ គ្រូត្រូវតែប្រើចំរៀកឬស្សីដូចបាននិយាយខាងលើនេះស្រាប់ ។

ឧបមាដូចជាៈ ចំរៀកឬស្សី ១៧ ថែមចំរៀកឬស្សី ២២ ទៀត តើត្រូវជាឬស្សីប៉ុន្មានចំរៀក ?

គ្រូត្រូវឲ្យសិស្សយកចំរៀកឬស្សី មកញែកឲ្យឃើញថា ក្នុង ១៧ ចំរៀកតើមានចំរៀកឬស្សីខ្ទង់ដប់ប៉ុន្មាន ចំរៀកឬស្សីរាយប៉ុន្មាន ឃើញថាចំរៀកឬស្សីខ្ទង់ដប់ ១ ចំរៀកឬស្សីរាយ ៧ ។ ចុះក្នុង ២២ ចំរៀកតើមានចំរៀកឬស្សីដប់ប៉ុន្មាន ចំរៀកឬស្សីរាយប៉ុន្មាន ឃើញថាចំរៀកឬស្សីខ្ទង់ដប់ ២ ចំរៀកឬស្សីរាយ ២ ដែរ ឲ្យសិស្ស

បញ្ចូលបំរៀកឬស្សីខ្ទង់ដប់ទៅលើបំរៀកខ្ទង់ដប់ បំរៀកឬស្សីរាយទៅលើរាយ តើត្រូវជាប៉ុន្មាន ឃើញថាបំរៀកឬស្សីខ្ទង់ដប់ ៣ បំរៀករាយ ៩ គឺ ៣៩ បំរៀក ។ ស្រេចហើយត្រូវតាំងលេខនៅក្ដារខៀនជាពីបែបបង្ហាញសិស្សទៀត ។

| | |
|---|---|
| ១៧ បំរៀក<br>+ ២២ –<br>៣៩ | ១៧ បំរៀក + ២២ = ៣៩ បំរៀក |

*អាទិត្យក្រោយ* — ចំនួនពី ៥០ ដល់ ១០០

បង្រៀនចំនួន–មើលចំនួននឹងសរសេរពី ៥០ ដល់ ១០០ ។

សូមគ្រូបង្រៀនចំនួនពី ៥០ ដល់ ១០០ ដោយប្រើបំរៀកឬស្សីដូចអាទិត្យទី ១ ។

---

មជ្ឈមដ្ឋានទី ១

## ធរណីមាណសាស្ត្រ

*អាទិត្យទី ១*

*អំពីបន្ទាត់តាំងឡាយ* .— ឲ្យសិស្សពិនិត្យមើលជ្រុងបន្ទាត់ផ្ដេក

ជើងតុ ធ្មេញរណារ ហាមមួក ហើយសួរឲ្យវាឆ្លើយអំពីរាងរបស់ទាំងនោះ ខ្លះតាមជ្រុងតុ ស្មានជា បន្ទាត់ត្រង់ ខ្លះស្មានដូចធ្មេញរណារ ស្មានជា បន្ទាត់កាច់ ហាមមួករាង បន្ទាត់កោង ។

ឲ្យសិស្សបង្ហាញរបស់ណាដែលមានស្មានដូចបន្ទាត់ទាំងនេះ

*លក្ខណៈនៃបន្ទាត់ត្រង់.–* ឲ្យសង្កេតមើលផ្ទៃទឹកក្នុងកែវ ស្មានជា បន្ទាត់ផ្ដេក ជើងតុសិស្ស ស្មានជា បន្ទាត់ឈរ ដម្បូលផ្ទះ ស្មានជា បន្ទាត់ឈៀង ។

ឲ្យសិស្សរករបស់អ្វី ដែលមានរាងដូចបន្ទាត់ត្រង់ទាំង ៣ មុខនោះ

*អាទិត្យទី ២*

*អំពីមុម.–* មុមមានប៉ុន្មានយ៉ាង មុមកែង មុមធ្លាយ មុមស្រួច ។

សុំមើលសៀវភៅក្បួនពន្ធអាទិកដ្ឋាន ទំព័រ ២៦

---

## រង្វាស់រង្វាល់

អំពីរង្វាស់រង្វាល់ជាប្រធាន ម៉ែត្រ លីត្រ ក្រាម រូបិយវត្ថុ ។

សុំលោកគ្រូលៃតាមពេលបង្រៀន ព្រោះខែសេបតមប្រ៍នេះមានតែ ១៥ ថ្ងៃ បើគិតទាំងបុណ្យប្រជុំបិណ្ឌផងនោះ មិនគ្រប់ ១៥ ថ្ងៃទេ ។

បង្រៀនអំពីម៉ែត្រ សុំលោកគ្រូរកម៉ែត្រគ្រប់មុខ គឺ ម៉ែត្រឈើ ១០ កំណាត់ ៥ កំណាត់ ត្រង់ដូចបន្ទាត់សំរាប់វាស់កំណាត់សំពត់ ម៉ែត្រសំពត់សំរាប់ជាងកាត់ខោអាវ ម៉ែត្រដែក-ស្ពាន់សំរាប់ជាងដែកជាងឈើ សាកសួរសិស្សអំពីប្រយោជន៍នៃម៉ែត្រមួយយ៉ាងៗ ហេតុអ្វីបានជាជាងកាត់ខោអាវមិនប្រើម៉ែត្របន្ទាត់ ហេតុអ្វីបានជាអ្នកលក់សំពត់មិនប្រើម៉ែត្រឈើបត់ ។

*ខ្នាតផលធំជាងប្រធាន:* (ម៉ែត្រ) សុំលោកគ្រូបញ្ជាក់សិស្សឲ្យចាំប្រាកដអំពី ដេកាម៉ែត្រ ហិកតូម៉ែត្រ គីឡូម៉ែត្រ ។

សុំបង្ហឹកសិស្សឲ្យប្រឹកនឹងខ្នាតខាងលើនេះ គឺឲ្យវាប្រែសព្ទពីមួយទៅមួយ ដូចជាឲ្យវារកក្នុង ១ គីឡូម៉ែត្រ មានប៉ុន្មានម៉ែត្រ ។ ប៉ុន្មានហិកតូម៉ែត្រ ។ ដេកាម៉ែត្រ ។

មជ្ឈដ្ឋានទី ២

## រង្វាស់រង្វាល់

*អាទិត្យទី ១*

*អំពីម៉ែត្រ* — ម៉ែត្រគឺជាខ្នាតប្រធាននៃរង្វាល់ប្រវែង

អំពីខ្នាតដែលធំជាងម៉ែត្រ; ដេកាម៉ែត្រ = ១០ ម៉ែត្រ ហិកតូម៉ែត្រ ១០០ ម៉ែត្រ គីឡូម៉ែត្រ ១.០០០ ម៉ែត្រ ។

ឱ្យសិស្សហាត់គិតមាត់ទទេ ប្តូរសព្ទមួយទៅមួយ ដូចជាឱ្យរកក្នុង ១៣១៧ ម៉ែត្រ មានប៉ុន្មានគីឡូម៉ែត្រ ក្នុង ១៥ គីឡូម៉ែត្រ មានប៉ុន្មានម៉ែត្រ ។

អំពីខ្នាតដែលខ្លីជាងម៉ែត្រ ដេស៊ីម៉ែត្រ សង្ទីម៉ែត្រ មីលីម៉ែត្រ សុំធ្វើឱ្យដូចខាងលើនេះ ។

***ការហាត់សរសេរ*** .— សុំលោកគ្រូជ្រើសរើសក្នុងសៀវភៅក្បួនពន្ធ លោក ប្រាសេត៍ ទំព័រ ១៥ ។

*អាទិត្យទី ២*

*អំពីរង្វាស់ប្រវែងដែលមានរូប* .— ជាប់តាំងពីខ្លីជាងម៉ែត្រ ១ ដេស៊ីម៉ែត្រ = ០ម,១០ ១ ម៉ែត្រ, កន្លះម៉ែត្រ ០ម,៥០ កន្លះដេកាម៉ែត្រ = ៥ម. ដេកាម៉ែត្រ ១០ ម៉ែត្រ ។

សុំឱ្យរកវង្វាស់ទាំងនោះ មកបង្ហាញឱ្យមើលឱ្យប្រើ

## ធរណីមាណសាស្ត្រ

*អាទិត្យទី ១*

*អំពីបន្ទាត់ទាំងឡាយ.–* បន្ទាត់ត្រង់ បន្ទាត់កោង បន្ទាត់កាច់ សុំគូរឱ្យមើល រូបបង្ហាញរាងរបស់ លក្ខណៈនៃបន្ទាត់ត្រង់ បន្ទាត់ផ្ដេក បន្ទាត់ឈៀង បន្ទាត់ឈរ បន្ទាត់ស្រប ។

*អាទិត្យទី ២*

អំពីមុមទាំងឡាយ មុមកែង មុមព្នាយ មុមស្រួច

*អំពីត្រីកោណ.–* គូរត្រីកោណមួយនៅក្ដារខ្មៀន ពិនិត្យមើលជ្រុងនឹងមុម រូបឱ្យរកន័យ ។

*លក្ខណៈនៃត្រីកោណ :* ត្រីកោណមិនស្មើជ្រុង ត្រីកោណស្មើជ្រុងពីរ ត្រីកោណស្មើជ្រុង ស្លាបក្ដោង ។

*រកផ្ទៃត្រីកោណ :* យកបាតទៅគុណនឹងពាក់កណ្ដាលកម្ពស់ ឬ ពាក់កណ្ដាលបាតគុណនឹងកម្ពស់ ឬ បាតគុណនឹងកម្ពស់ រូបបែកនឹងពីរ ។

ឲ្យសិស្សហាត់គិតមាត់ទទេ រកផ្ទៃក្រឡាចំនួនដែលងាយ ដូចជាស្រែមួយរាងត្រីកោណបាតប្រវែង ៨ម. កម្ពស់ ៤ម. តើស្រែនោះមានប៉ុន្មានម៉ែត្រក្រឡា ។

សុំឲ្យសិស្សហាត់គិតបែបនេះឲ្យច្រើន ។

ការហាត់សរសេរ – សុំគ្រូរើសផងចុះ ។

អាទិកដ្ឋាន

**ពន្ធ**

យើងត្រូវចាំថាសេចក្ដីប្រែប្រួលសួប់ជាការមានប្រយោជន៍ធំណាស់ ដូចជាក្នុងវិជ្ជាពន្ធនេះ បើក្មេងរាប់ឬគិតលេខបាខ្លាំង ៗ ក្នុងឯទៀតៗ ហើយ ក៏ចាំចំនួនដែលរកឃើញនោះ មិនចាំបាច់ឃើញគេសរសេរចំនួននោះទេ ។

បើត្រូវឲ្យចំណាំរៀបរាប់ឈ្មោះអ្វី ៗ ក្នុងសេចក្ដីណាមួយ ត្រូវបង្ហាត់ឲ្យសិស្សនិយាយខ្លាំង ៗ ប៉ុន្តែត្រូវហៅឲ្យគ្រប់សិស្សម្នាក់ ៗ បញ្ជាក់សេចក្ដីដែលវាថានោះផង ក្នុងវិជ្ជាផ្ទាស់ផ្ទាល់ ក៏ត្រូវហ្វឹកហ្វឺនដូច្នេះដែរ ។

*អាទិត្យដំបូង*.— លេខបូកនឹងលេខសងចំនួនពី ១ ដល់ ១០០ គឺមានលេខពីរខ្ទង់ ។

វេលាដែលបង្រៀននព្វន្តនោះ កុំឲ្យបង្រៀនតែលេខទទេ ត្រូវឲ្យមានវត្ថុអ្វីផ្សេងៗ ដូចជាដុំក្រួស ដងប៉ាកកា ឬខ្មៅដៃ ដើម្បីឲ្យសិស្សរៀនរាប់ ។

*វិធីហាត់សរសេរ*

| | | | | |
|---|---|---|---|---|
| ១៧៛ | ២៥៛ | ៣៤៛ | ៣៩៛ | ៥៤៛ |
| +៣២៛ | +២១៛ | +១៣៛ | −១៥៛ | −២៩៛ |

## បំណោទ

*១.— ពេលព្រឹកខ្ញុំចាយ ១៧ សេន ពេលថ្ងៃរសៀលខ្ញុំចាយ ១៤ សេន ពេលល្ងាចខ្ញុំចាយ ៣ សេន ។ ក្នុងមួយថ្ងៃខ្ញុំចាយអស់···សេន ។*

*២.— ខ្ញុំស៊ីឈ្នួលគេបាន ២៧ រៀល ខ្ញុំចែកទៅប្អូនខ្ញុំ ៦ រៀល ខ្ញុំនៅសល់····រៀល ។*

*អាទិត្យក្រោយ*.— លេខបូកនឹងលេខសងចំនួនពី ១ ដល់ ១០០ មានលេខពីរខ្ទង់ "មើលសៀវភៅក្បួននព្វន្តអាទិកដ្ឋាន ទំព័រទី ២០" ។

## វិធីបកគិតមាត់ទទេ

$២៤^{២} - ៥^{២} = \ldots$ ។ $២៩^{២} + ៣^{២} = \ldots$ ។ $២៣^{២} + ៨^{២} = \ldots$ ។ $២៥^{២} + ៩^{២} = \ldots$

$៣១^{២} - ៤^{២} = \ldots$ ។ $៣៤^{២} - ៥^{២} = \ldots$ ។ $៣៥^{២} - ៩^{២} = \ldots$ ។ $៣២^{២} - ៩^{២} = \ldots$

$២៦^{២} - ៧^{២} = \ldots$ ។ $២៧^{២} + ៣^{២} = \ldots$ ។ $៣២^{២} - ៤^{២} = \ldots$ ។ $២៩^{២} - ៧^{២} = \ldots$

*សូមឲ្យសិស្សរាប់បន្ថែមបួនៗ ប្រាំមួយៗ ប្រាំពីរៗ តាំងពី ៤៣ ឡើងទៅមិនឲ្យហួស ៨០ រួចរាប់បន្ថយបួនៗ ប្រាំមួយៗ ប្រាំពីរ មិនឲ្យហួស ៣០ ។*

## បំណោទ

*១.— ចៅកង៍ទិញពងមាន់ ២៩ វាធ្វើឲ្យបែកអស់ ៧ តើចៅកង៍នៅសល់ពងមាន់ប៉ុន្មាន ។*

*២.— ចៅសួនមានលុយ ២៥ សេន វាចាយម្តងអស់ ៧ សេន ម្តងទៀត ៩ សេន តើចៅសួននៅសល់ប៉ុន្មានសេនទៀត ។*

## រង្វាស់រង្វាល់

### *ពាក្យដំបូង* ម៉ែត្រ

ត្រូវយកម៉ែត្រគ្រប់យ៉ាងមកបង្ហាញសិស្ស ហើយសូមពន្យល់អំពីរាងម៉ែត្រ នឹងបំណែកម៉ែត្រ រួចស្រេចហើយ ទើបឲ្យរៀនវាស់បណ្តោយ ទទឹង តុ ទូ សៀវភៅ ។ល។

*សេចក្ដីបន្ថែម.—* មានម៉ែត្រច្រើនយ៉ាង គឺម៉ែត្រឈើបត់ ម៉ែត្រឈើបន្ទាត់ ម៉ែត្រដែកឬស្ពាន់បត់ ម៉ែត្រសំពត់ ។ ម៉ែត្រនោះសុទ្ធតែប្រវែងស្មើគ្នាទាំងអស់ ។ ម៉ែត្រឈើបត់ នឹងម៉ែត្រដែកឬស្ពាន់បត់ សំរាប់វាស់បណ្ដោយ-ទទឹង កំពស់ត្នុទ្វ ជញ្ជាំង ។ ម៉ែត្រឈើបត់សំរាប់វាស់សំពត់គ្រប់មុខ ។ ជាងកាត់អាវ ប្រើម៉ែត្រសំពត់ ។ ក្នុងមួយម៉ែត្រមាន ១០ ដេស៊ីម៉ែត្រ ឬ ១០០ សង់ទីម៉ែត្រ ។

*វិធីហាត់គិតមាត់ទទេ*

ក្នុង ១ ម៉ែត្រមានប៉ុន្មានដេស៊ីម៉ែត្រ ។ ក្នុង ២ ដេស៊ីម៉ែត្រមានប៉ុន្មានសង់ទីម៉ែត្រ ។

*ភាគិតប្រក្រោយ.—* អំពីលីត្រ

(យកតាមក្បួនពន្ធបដិញ្ញាណដ្ឋានទំព័រ ២១) សូមបង្ហាត់បង្ហាញតាមរបៀបដូចបង្រៀនម៉ែត្រ ។ មានលីត្រច្រើនយ៉ាង លីត្រសំណប៉ាហាំង សំរាប់វាស់វត្ថុរាវ (ទឹកប្រេងកាតទឹកដោះគោ) លីត្រឈើសំរាប់វាល់គ្រាប់ (អង្ករ សណ្ដែក) ។ ទឹកមួយលីត្រទម្ងន់មួយគីឡូក្រាម ។ ក្នុងមួយលីត្រមាន ១០ ដេស៊ីលីត្រ ឬ ១០០ សង់ទីលីត្រ ឬ ១០០០ មីលីលីត្រ ។

មធ្យមសិក្សា

# វង្វាស់វង្វាល់

*អាទិត្យដំបូង* – អំពីម៉ែត្រ

*របៀបបង្រៀន*

*ប្រដាប់បង្រៀន* – ម៉ែត្រទាំងបីយ៉ាងគឺៈ ម៉ែត្របន្ទាត់ ១ ម៉ែត្របត់ ៥ ឬ ១០ ផ្នត់ ១ ម៉ែត្រសំពត់ ១ មានម៉ែត្រឈើ-ស្ពាន់-ដែក ខ្សែ ១ បង្ហាយ ។

*របៀបបង្រៀន* – សូមលើកម៉ែត្រណា ១ ឲ្យខ្ពស់ឡើងបង្ហាញឲ្យសិស្សឃើញគ្រប់គ្នា ។ ឲ្យសិស្សពិនិត្យរូបរាងម៉ែត្របន្ទាត់ ម៉ែត្របត់ ម៉ែត្រសំពត់ ។ សួរសិស្សថា នេះអ្វី? គេហៅថាម៉ែត្រអ្វី? ធ្វើអំពីអ្វី? (ធ្វើបែបនេះ ១ លើកម្តងគ្រប់ម៉ែត្រទាំងអស់) – ម៉ែត្រទាំងអស់ដូចគ្នាឬទេ? ហេតុដូចម្តេចបានជាគេធ្វើឲ្យខុសគ្នាយ៉ាងនេះ? (ប្រើការមិនដូចគ្នា) – ប្រវែងគ្នាឬទេ? (ឲ្យសិស្សម្នាក់ ឬពីរនាក់ឡើងមកឈរនៅមុខតុសរសេរ លោកគ្រូ ... កម៉ែត្រទាំងប៉ុន្មានមកវាស់ផ្ទៀងគ្នាមើលឲ្យឃើញជាក់ជាប្រវែងគ្នាមែន) – ល្បួងមើលទៅ

សិស្សឯទៀតថា ម៉ែត្រទាំងនេះតើម៉ែត្រណាវែងជាង? ណាខ្លីជាង? – គេធ្វើម៉ែត្របន្ទាត់ប្រើការវាស់អ្វី? – (សំពត់) – អ្នកណាប្រើម៉ែត្របត់? – (ជាងឈើ – ជាងធ្វើផ្ទះ) – ព្រោះអ្វី គេធ្វើម៉ែត្របត់សម្រាប់ជាងឈើ (ងាយដាក់ជាប់ទៅនឹងខ្លួន) – ជាងណាប្រើម៉ែត្រសំពត់? (ជាងកាត់ខោអាវ) – ហេតុដូចម្ដេច? (ងាយវាស់កន្លែងមូលដូចជុំវិញបង្កេះ – ជើង – ដៃ.......) ។ល។

ដូច្នេះម៉ែត្រទាំងឡាយតើគេប្រើធ្វើអ្វី? (វាស់ទទឹង-បណ្ដោយ កំពស់-ជុំវិញ......) ។ល។ វត្ថុទាំងឡាយ ។

*ពាក្យសួរពោលទៅសិស្ស* បើសិស្ស-ឆ្លើយមិនត្រូវ-មិនរួច ត្រូវផ្លាស់របៀបសួរ សួរចំពោះលើសិស្សទាំងអស់ បើសិស្សណាឆ្លើយត្រូវសឹមលោកគ្រូប្រាប់ឲ្យសិស្សម្នាក់ថាតាម ឬឲ្យសិស្សច្រើននាក់ទៀតថាតាម ធ្វើដូច្នេះដើម្បីញ៉ាំងសតិសិស្សឲ្យចាំច្បាស់ប្រាកដ ។

*របៀបវាស់* – ហៅសិស្សម្នាក់មកឈរនៅកណ្ដាលបន្ទប់រៀន ឲ្យយកម៉ែត្របន្ទាត់នឹងខ្សែមួយបង្ហាយឲ្យវាស់ប្រវែងខ្សែនោះ ។ រួចហើយសួរទៅសិស្សណាដែលលោកគ្រូសង្ស័យថាមិនប្រុងស្ដាប់ សួរថាខ្សែមួយបង្ហាយនេះប្រវែងប៉ុន្មានម៉ែត្រ ។

ហៅម្នាក់ទៀត ឲ្យយកម៉ែត្របត់ទៅវាស់ទទឹង-បណ្ដោយ-កំពស់តុគ្រូ តុរបស់សិស្សនឹងបន្ទប់រៀន ... ។ល។ វាស់ហើយសួរបញ្ជាក់ទៅសិស្សដែលអង្គុយស្ដាប់ឲ្យថា តុនោះប្រវែងប៉ុន្មានម៉ែត្រ។

ឲ្យសិស្សម្នាក់ទៀតយកម៉ែត្រសំពត់ វាស់ជុំវិញក្បាល-បង្កេះគ្រូកនវាម្នាក់ ។

ធ្វើយ៉ាងនេះ ទើបសិស្សអាចយល់ប្រាកដ ចាំជាក់ដោយយកចិត្តទុកដាក់ផង ដោយបានឃើញជាក់នឹងភ្នែកផង ។

គេទិញសំពត់ ៩ ម៉ែត្រ គេកាត់យកម្ដង ២ ម៉ែត្រ ម្ដងទៀត ១ ម៉ែត្រ រួប ៣ ម៉ែត្រទៀត គេកាត់ប៉ុន្មានម៉ែត្រ នៅសល់ប៉ុន្មានម៉ែត្រទៀត ។

ឯការហាត់គិតមាត់ទទេ ឬសរសេរ សូមលោកគ្រូលៃលកធ្វើផងចុះ ។

*វាក្យក្រោម — អំពីលីត្រ*

*របៀបបង្រៀន* — សូមយកលីត្រដែកស៊ីទ្បាត លីត្រស្ពាន់ស លីត្រដបមកឲ្យសិស្សពិនិត្យមើល (បើគ្មាននៅសាលាសូមខ្ចីអ្នកជិតខ្លួញ) ប្រាប់សិស្សថា លីត្រ ពិតមែនជារាងខុសគ្នា ប៉ុន្តែចំណុះស្មើគ្នាទាំងអស់ គេធ្វើរាងខុសគ្នា ពីព្រោះប្រើការផ្សេងពីគ្នា ។

លីត្រធ្វើនឹងដែកសីវីឡាតមានដែកកាន់ពីក្រោយនេះ សំរាប់វាល់របស់រាវ ដូចជាខ្លាញ់ ប្រេង ទឹក ។ល។

លីត្រធ្វើនឹងស្ពាន់សរមានដៃយួរនេះ សំរាប់វាល់ស្រា ទឹកដោះគោ ។ល។

លីត្រធ្វើនឹងឈើនេះសម្រាប់វាល់របស់ក្រៀម ឬគ្រាប់ឈើដូចជាម្សៅ ពោត អង្ករ ស្រូវ ។ល។

លីត្រទាំងឡាយគេធ្វើនេះប្រយោជន៍វាល់របស់ណា ដែលគេវាល់ឬថ្លឹងមិនបាន សូមបង្ហាញគំនូររូបនៅសៀវភៅក្បួនពុទ្ធបរិវត្តណាដ្ឋានទំព័រ ២៧

របៀបវាល់-ពេលបង្រៀន ត្រូវរកទឹក អង្ករ ឬស្រូវ ។ល។ ឲ្យសិស្សម្នាក់ឬពីរនាក់មកហាត់វាល់ ឲ្យសិស្សឯទៀតប្រុងស្មារតីចាំមើល ហើយសូមបង្ហាញចំនួនមួយលីត្រពីរលីត្រ ។ល។ ត្រូវបង្រៀនសិស្សឲ្យចេះវាល់វត្ថុផ្សេងៗផង ។

ពាក្យសួរ លីត្រមានប៉ុន្មានយ៉ាង? ធ្វើពីអ្វី? ប្លែកគ្នាដូចម្ដេច? សំរាប់ធ្វើអ្វី? ... ល ។

សូមតែងការហាត់ហើយនឹងបំណោទឲ្យធ្វើផង ដូចបានពន្យល់ពីម៉ែត្រស្រាប់ ។

## កុមារដ្ឋាន

### គណិត

*បង្រៀនចំនួនពី ០ ដល់ ៩*

ក– របស់ដែលត្រូវយកមកបង្ហាញសិស្ស.– បង្កើះ ដុំក្រួស, ប្រាក់, សេន, ដីស....ល.... ។

១– របៀបបង្រៀន.–

ចំនួន ០.– ១– គ្រូលើកដៃទទេបង្ហាញសិស្ស ហើយសួរសិស្សថា ក្នុងដៃលោកគ្រូមានបង្កើះប៉ុន្មាន - គ្មាន ឬ សូន្យ ពាក្យ "គ្មាន" ឬ "សូន្យ" នេះ ត្រូវឲ្យសិស្សថា ឲ្យបានច្រើនគ្នា ។

២– គ្រូសរសេរលេខ ០ នៅក្ដារខៀនបង្ហាញសិស្ស ឲ្យសិស្សមើល, ឲ្យសិស្សសរសេរនៅក្ដារខៀន ហើយនឹងនៅក្ដារឆ្នួន លើកឲ្យគ្រូមើលពិនិត្យឲ្យ ត្រឹមត្រូវ ។ (លេខក្រោយៗមកទៀតក៏ត្រូវធ្វើដូច របៀបនេះដែរ) ។

៣- គ្រូសួរឲ្យសិស្សគិត.- ឯងអានមួកឬទេ? (គ្មាន ឬសូន្យ)- ឯងមានរទេះឡាន ឬរទេះកង់ឬទេ? (គ្មាន ឬ សូន្យ) ។ល។

ចំនួន ១.- ១- គ្រូកាន់បង្គោះ ១ ហើយប្រាប់សិស្សថា នេះ បង្គោះ (១) ។

២- គូសគំនូសបង្គោះ ១ នៅក្ដារខៀន ។

៣- គ្រូសរសេរលេខ ១ នៅក្រោមគំនូស (ធ្វើដូចជា លេខ ០)

៤.- គ្រូសួរឲ្យសិស្សគិត.- ឯងមានក្បាលប៉ុន្មាន? មានមាត់ប៉ុន្មាន? មានច្រមុះប៉ុន្មាន? ...ល...។

៥.- គ្រូសួរឲ្យសិស្សបង្ហាញ.- ចូរឯងបង្ហាញតុមួយ- ទូមួយ-កៅអីមួយ...ល... ។

ចំនួន ២. ១- គ្រូកាន់បង្គោះ ១ នៅដៃស្ដាំ ហើយ ១ ទៀត នៅដៃ ឆ្វេង រួចប្រមូលបង្គោះទាំង ២ នៅក្នុងដៃ តែម្ខាង ហើយប្រាប់សិស្សថាៈ នេះបង្គោះ២-

២– គ្រូគូសគំនូសបង្កើះ២ នៅក្ដារខៀន ហើយត្រា លេខ ២ ពីក្រោម (ធ្វើដូចជាលេខ ១) ។

៣– គ្រូសួរឲ្យសិស្សគិត.– ឯងមានដៃ, ជើង, ភ្នែក, ត្រចៀក, ប៉ុន្មាន? ក្នុងថ្នាក់យើងមានក្ដារខៀន ប៉ុន្មាន....ល....។

ចំនួន ៣.– ១– គ្រូបង្ហាញបង្កើះម្ដង ១ ៗ គ្រប់ ៣ ហើយទើប ប្រាប់សិស្សថា: នេះបង្កើះ ៣ ។

២– គ្រូគូសគំនូស ៣ ហើយត្រាលេខ ៣ ពីក្រោម (ធ្វើដូចជាលេខ ២) ។

៣– គ្រូសួរសិស្សឲ្យគិត.– (គ្រូគោះតុ ៣ ដង) ឯង ឮសួរប៉ុន្មានដង? (គ្រូឲ្យលុយ៣សេនទៅសិស្ស) ឯងមានលុយប៉ុន្មានសេន? មុមបង្អួចមានប៉ុន្មាន ប្រឯងដើរ ៣ ជំហាន...ល...។

ចំនួន ៤.– ១– គ្រូបង្ហាញបង្កើះម្ដង ២ ៗ ប្រាប់សិស្សថា នេះ បង្កើះ ៤ ។

២– បង្រៀនដូចលេខមុន ៗ ។

៣– គ្រូសួរសិស្សឲ្យគិត.– តុនេះមានកូនសិស្ស ប៉ុន្មាននាក់? (បង្ហុលតុណាដែលមានសិស្ស អង្គុយ៤នាក់)។ គោ, ក្របី, សេះ, ដំរី, ឆ្កែ, ជ្រូក,.. សត្វអស់នេះមួយៗ មានជើងប៉ុន្មាន?..ល..។

ចំនួន ៥-៦-៧-៨-៩ = បង្រៀនដូចលេខមុនៗ

គ្រូសួរឲ្យសិស្សគិត.– ឯងមានម្រាមដៃប៉ុន្មាន? ម្រាមជើងប៉ុន្មាន? (ឲ្យបង្គើះ ២០ ទៅសិស្សម្នាក់ឲ្យវាចែកជា ៤ បាច់) តើ ១ បាច់មានបង្គើះ ប៉ុន្មាន...ល...។

៤– បង្រៀនគិតរកចំនួននឹងប្រាជ្ញា (មតិសំខាន់) គ្រូ ហោះថា តុ ៣ បើថែមតុ ២ ទៀតត្រូវជាតុប៉ុន្មាន? (ឆ្លើយមាត់ទទេ) ។

បើដក ២ ពី ៣ ចេញ តើនៅសល់ប៉ុន្មាន? គ្រូ មានខ្មៅដៃ ៥ បើចែកឲ្យសិស្សអស់ ៣ តើនៅ សល់ខ្មៅដៃប៉ុន្មានទៀត?

## រង្វាស់រង្វាល់

*អំពីម៉ែត្រ*

ត្រូវយកម៉ែត្រគ្រប់យ៉ាងបើរកបាន គឺៈម៉ែត្របត់ ៥ ផ្នត់ ឬ ១០ ផ្នត់ ធ្វើនឹងឈើឬស្ពាន់ សំរាប់វាស់ ទទឹង បណ្ដោយ កំពស់ សារពើគ្រប់ជំពូក ម៉ែត្រឈើត្រង់ ឬម៉ែត្របន្ទាត់ សំរាប់វាស់សំ-ពត់ផ្សេងៗ ម៉ែត្រសំពត់សំរាប់វាស់ទំហំខ្លួន បណ្ដោយខ្លួននឹងដៃ ដែលជាងកាត់ខោអាវប្រើសព្វថ្ងៃនេះ ។

ឯម៉ែត្រទាំងអស់នេះមានរាងនឹងទំហំខុសអំពីគ្នា ប៉ុន្តែបណ្ដោយប្រវែងគ្នាទាំងអស់ ហេតុនេះបានជាហៅថាម៉ែត្រដូចគ្នា ។

ហេតុដូចម្ដេចបានជាគេធ្វើម៉ែត្រច្រើនបែបយ៉ាងនេះ ដើម្បីឲ្យងាយវាស់ ព្រោះរូបរបស់ដែលគេវាស់នោះផ្សេងៗពីគ្នាដែរ ។

*ក— ការពិនិត្យមើលរង្វាស់ ម៉ែត្រ (ម៉ែត្រឈើបត់ឬត្រង់)*

១— គ្រូបង្ហាញម៉ែត្រ ហើយប្រាប់សិស្សថានេះគឺៈ រង្វាស់ឈ្មោះថាៈ ម៉ែត្រ ។

ឲ្យសិស្សកាន់ហើយពិនិត្យ (ប្រវែង, ទំហំ, រាង, ពណ៌, លេខ, ទម្ងន់, ជាតិឈើ······)

២ – គ្រូសរសេរពាក្យ "ម៉ែត្រ" នៅក្ដារខៀន (សរសេរគ្រប់តួអក្សរ និងសរសេរកាត់ "ម") ហើយឲ្យសិស្សមើល។

៣– គ្រូសួរសិស្សឲ្យរករបស់អ្វី ណាមួយនៅក្នុងកន្លែងរៀន ដែលមានបណ្ដោយ ឬ ទទឹង ឬ កំពស់ ចំនួនប្រវែង១ ម៉ែត្រ (ឧទាហរណ៍ ទទឹងក្ដារខៀន, ទទឹងតុគ្រូ, ទទឹងទ្វារ····ល····។)

៤ – គ្រូហៅសិស្សប្រើនរូបម្នាក់ម្ដង ឲ្យទៅគូសបន្ទាត់ប្រវែង ១ ម៉ែត្រ នៅក្ដារខៀន ។ រួចសិស្សយកម៉ែត្រទៅវាស់ តើសិស្សណាបានគូសត្រឹមត្រូវ ១ ម៉ែត្រ ។

*ខ – វិធីវាស់ប្រវែងរបស់ផ្សេងៗ ដោយស្មាន*

*និងវិធីវាស់បញ្ជាក់នឹងម៉ែត្រ*

១ – គ្រូប្រាប់សិស្សឲ្យស្មាន តើកន្លែងរៀនមានបណ្ដោយ ប្រវែងប៉ុន្មានម៉ែត្រ ។

២ – សិស្សស្មានហើយ ត្រាពាក្យឆ្លើយនៅក្ដារឆ្នួនរៀងខ្លួន។

៣– គ្រូត្រូវតែត្រាមើល បើឃើញសិស្សណាឆ្លើយស្មានខុសច្រើនពីសិស្សដទៃ ឱ្យសិស្សនោះយកម៉ែត្រទៅវាស់បណ្ដោយកន្លែងរៀន ដើម្បីឱ្យសិស្សនោះដឹងថាវាឆ្លើយខុស ។

(ក្នុងពិធីវាស់នេះ គ្រូត្រូវបង្ហាញសិស្សឱ្យបានឃើញច្បាស់គ្រប់គ្នា ពីរបៀបកាត់ម៉ែត្រវាស់ឱ្យត្រឹមត្រូវ) ។

៤- រកប្រវែងរបស់ផ្សេងៗ ឱ្យសិស្សស្មានឆ្លើយ ហើយឱ្យបានវាស់ឱ្យច្រើនដង ។

*គ — ការហាត់នៅក្ដារឆ្នួនឬនៅក្នុងសៀវភៅ*

គ្រូឱ្យបំណោទមួយយ៉ាងខ្លី (បំណោទនេះមិនបាច់សរសេរនៅក្ដារខៀនទេ បើឱ្យសិស្សធ្វើនៅក្ដារឆ្នួន) ដែលមានលេខបូកឬសងឬគុណឬចែក គឺលេខណាដែលសិស្សបានរៀនរួចហើយ ។ ឯសិស្សគ្រាន់តែត្រាលេខឆ្លើយនៅលើក្ដារឆ្នួន ហើយលើកជូនគ្រូពិនិត្យ ។

អាទិកដ្ឋាន

## វត្ថុស្វាធ្យាយន៍

*អង្គកាយមនុស្ស (បំណែកខ្លួន)*

ពីមុន គេបានពន្យល់ពីប្រយោជន៍នឹងរបៀបបង្រៀនវត្ថុស្វាធ្យាយន៍រួចហើយ សូមលោកគ្រូមើលក្នុងកិច្ចសិក្សាពីឆ្នាំមុនចុះ ។

*មេរៀនទី ១.—* ការពិនិត្យឲ្យសិស្សម្នាក់ឈរនៅមុខសិស្សឯទៀត ហើយចង្អុលបង្ហាញសិស្សអំពីបំណែកនីមួយៗនៃខ្លួនមនុស្ស ប្រាប់ថានេះក្បាល នេះដងខ្លួន នេះដៃ (អវយវៈលើ) នេះជើង (អវយវៈក្រោម) ។ បង្គាប់សិស្សពីរនាក់ឲ្យមកឈរនៅមុខសិស្សទាំងពួង ហើយសួរឲ្យពិនិត្យថាវាដូចគ្នាឬទេ អំពីអង្គកាយ អំពីកំពស់-ទំហំ-រូបរាង-មុខមាត់-បែបភាព ។ ឲ្យសិស្សវាស់ទំហំក្បាល ទំហំដងខ្លួន ប្រវែងដៃជើងគ្នាវាមើល ។

*ពាក្យសួរ.—* ខ្លួនមនុស្សមានប៉ុន្មានបំណែក ។ អ្វីខ្លះ ។ ក្បាលយ៉ាងដូចម្ដេច ។ នៅលើក្បាលមានអ្វី ។ ដៃនៅឯណា ។ ដៃជាប់នឹងក្បាលនឹងអ្វី ។ គេលើកដៃបានឬទេ ។ ជើងនៅឯណា ។ ជើងសំរាប់ប្រើធ្វើអ្វី ។

*មេរៀន.—* ខ្លួនមនុស្សមានបីបំណែក គឺ ក្បាល-ដៃ-ជើង ។ ក្បាលមូល មានសក់ដុះជិត ។ មានដៃពីរសំរាប់ចាប់កាន់ នឹងជើងពីរសំរាប់ដើរ ។

*មេរៀនទី ២.—* ការពិនិត្យហើយពិចារណា ឲ្យសិស្សស្ទាប ក្បាលវាឲ្យដឹងថាមានរលោ (រលោដូចដែលវាបានឃើញហើយ) លលាដ៍ក្បាលរឹងអាចឲ្យដុះសក់ ដូចជាផែនដីអាចឲ្យដុះស្មៅ ។ ឲ្យបត់ដៃ-លាតដៃ-លើកដៃ ឲ្យគន់មើលសន្លាក់នឹងម្រាម ។ ឲ្យ មើលមុខគូកនវា តើមានអ្វីខ្លះ ភ្នែក, ច្រមុះ, ត្រចៀក, មាត់ ។ ឲ្យ លើកជើង-សណ្ដូក-បត់ជើង ឲ្យក្រោកឈរ ដើរ-រត់ ។ ដងខ្លួន ដូចអ្វី កំរើកបានឬទេ ឲ្យសិស្សពត់ខ្លួនទៅស្ដាំទៅឆ្វេង ។

*ពាក្យសួរ.—* លលាដ៍ក្បាលដូចអ្វី ។ មានអ្វីលើលលាដ៍ ក្បាល ។ មុខនៅឯណា ។ល។

*មេរៀនខ្លួន.—* លលាដ៍ក្បាលរឹង មានសក់ដុះពេញ ។ ដង ខ្លួនដូចជាសសរ ប៉ុន្តែមិនរឹងស្ដូកទេ ។ លើដងខ្លួន ខាងមុខមាន ទ្រូងនឹងពោះ ខាងក្រោយមានខ្នង ។ ដៃជាប់ទៅដងខ្លួនខាងលើ ជើងជាប់ទៅដងខ្លួនខាងក្រោម ។ កំរើកដៃនឹងជើងបានងាយជាង កំរើកក្បាលហើយនឹងខ្លួន ។

## វិធីបង្ការរោគ

វិធីបង្ការរោគជាក្បួនដែលបង្ហាញឲ្យជនទាំងឡាយ ប្រតិបត្តិ

តាមដើម្បីការពារខ្លួននឹងជម្ងឺផ្សេងដូចជាកមរមាស់ - អុត - កញ្ជ្រិល ឈឺភ្នែកជាដើម ។ អ្នកណាទៅប៉ះពាល់នឹងមនុស្សមានជម្ងឺឆ្លង អ្នកនោះនឹងមានជម្ងឺដូចគេដែរ លើកតែជនណាប៉េះការពារខ្លួនដោយហ្មត់ចត់ណាស់ ទើបចៀសវាងជម្ងឺឆ្លងនោះ ន ។ កិច្ចដែលត្រូវធ្វើដើម្បីចៀសវាងជម្ងឺឆ្លងបាន គឺការសំអាតជាធំបំផុត រួបបាក់ហ្នឹបង្ការរោគ ត្រូវសំអាតខ្លួន - សំលៀកបំពាក់ - បំណីអាហារនឹងទឹកផឹក ។ គេឃើញជារឿយៗ ក្នុងវង្សត្រកូលមួយ ឪពុក - ម្ដាយ - កូនទាំងអស់កើតកមរមាស់ឬឈឺភ្នែក ។ ហេតុអ្វីបានជាមនុស្សទាំងអស់នេះមានជម្ងឺដូចគ្នា ។ គឺពីព្រោះវាប៉ះពាល់ផ្ទាល់គ្នាហើយមិនប៉េះការពារខ្លួននឹងជម្ងឺឆ្លងនេះ ។ ដូច្នេះត្រូវរៀនឲ្យប៉េះវិធីបង្ការរោគ ។

មេរៀនទី ១ - ការសំអាតខ្លួន

បួលអ្នកងូតទឹកឲ្យបានប្រើនដងមួយថ្ងៃ ដោយហោចណាស់ឲ្យបានពីរដង គឺព្រឹក - ល្ងាច ។ កុំងូតតែទឹកទទេ ត្រូវដុសសាប៊ូឲ្យសព្វខ្លួនទាំងអស់ ហើយយកកន្សែងដុសឈើលើសាប៊ូនោះរួបស្រោចទឹកលាងខ្លួនឲ្យជ្រះបេញ ហើយយកកន្សែងស្ងួតជូតខ្លួនឲ្យជ្រះបេញទៀត ។

*ការពិនិត្យបញ្ចប់* — សូមលោកគ្រូពិនិត្យសិស្សរាល់ពេលមុនចូលរៀន តើវាបានធ្វើតាមសេចក្ដីរៀនឬទេ បើឃើញសិស្សណាមានក្អែលឬប្រឡាក់ដៃនឹងធូលី ត្រូវឲ្យត្រឡប់ទៅងូតទឹកឬលាងដៃវិញ ។

*មេរៀនទី២* — ការសំអាតសម្លៀកបំពាក់-សុំធ្វើដូចអាទិត្យមុន

បរិច្ឆេទ៨

## វិត្តស្វាធ្យាយន៍

*អាទិត្យទី១* — អំពីខ្លួនមនុស្ស

ហៅសិស្សម្នាក់មកឲ្យដោះអាវចេញ ហើយឈរនៅមុខសិស្សឯទៀតទាំងអស់ រួចឲ្យសង្កេតមើលរូបកាយយើង ខ្លួនយើងមាន ៣ បំណែក ក្បាលនៅខាងលើ និងខ្លួននៅកណ្ដាល និងអវយវៈ (ដៃ-ជើង ។ ពិនិត្យមើលរាងក្បាលប្រៀបនឹងក្បាលគូកនវា គេឃើញមានអ្វីខ្លះនៅខាងមុខ ខាងលើ ខាងក្រោយ ក្បាលភ្ជាប់ទៅខ្លួននឹងអ្វី ។ ពិនិត្យមើលដៃជើង បំណែកនៃដៃជើង ផ្ទឹមគ្នាមើលដោយប្រវែង ដោយទំហំ ហើយឲ្យសំគាល់អំពីដៃជើងបត់និងកំរើក

បុះឡើងបានដោយសារអ្វី (សន្លាក់) ។ ពិនិត្យជងខ្លួន បំណែកខាងលើ (ទ្រូង) ខាងក្រោយ (ខ្នង) ខាងក្រោម (ពោះ) ស្មា (ភ្ជាប់ដៃ) អវយវក្រោម ជាប់ទៅខ្លួននឹងត្រគាក – សុំមើល ហើយបង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់បរិប្ចូណាដ្ឋានទំព័រទី ៣ និងទី ៤ មានសេចក្ដីសង្ខេបជាស្រេចហើយ ។

២ – អដ្ឋិសង្ខលិក ក្បាលនឹងជងខ្លួន (បើរកឆ្អឹងឲ្យសិស្សមើលបានគួរយកមកឲ្យសិស្សមើល ឲ្យប្រាប់ខ្លួនយើងមើល មានខ្លះទន់ជ្រាយ ខ្លះរឹង បំណែកទន់គឺ (សាច់) បំណែករឹងគឺឆ្អឹង ។

ឆ្អឹងក្នុងខ្លួនយើងទាំងអស់ប្រមូលរួមទៅហៅថា (អដ្ឋិសង្ខលិក)។ ពិនិត្យឆ្អឹងក្បាល ។ ៣ ឆ្អឹងនៅជងខ្លួន ។ ៤ ឆ្អឹងអវយវ សុំមើលហើយបង្រៀន តាមសៀវភៅទំព័រទី ៥ ទី ៦ – ។

៣ – ឆ្អឹងសន្លាក់ឬគណ្ឋិក

ត្រូវរកឆ្អឹងមកឲ្យសិស្សមើលខ្លះ ឬបង្ហាញគំនូរ ពិនិត្យខ្លួនយើងគ្រប់កន្លែង មើលទ្រង់ទ្រាយ ទំហំឆ្អឹងយើងទាំងប៉ុន្មាន ។ ឆ្អឹងខ្លី វែង ។ ពិនិត្យសន្លាក់គ្រប់កន្លែង សន្លាក់ខ្លះកំរើកបានងាយ ខ្លះមិនសូវងាយ ហេតុអ្វី ។

សុំមើលបង្រៀនតាមសៀវភៅទំព័រទី ៨ – ៩ – ១០ – ។

*អាទិត្យទី២* – អដ្ឋិសង្ខលិក អវយវ

សុំធ្វើដូចអាទិត្យទី ១ ហើយមើលសេចក្ដីនេះ ក្នុងទំព័រទី ៦ – ៧ – ៨ – ។

## វិធីបង្ការរោគ

*វិធីហាត់ប្រាណ*

ឲ្យសិស្សពិនិត្យមើលរូបរាងកាយអ្នកស្រែចំការ នឹងអ្នកធ្វើការរាជការ តើខុសគ្នាយ៉ាងណា ដោយសារអ្វី ។ បើដូច្នេះត្រូវធ្វើដូចម្ដេចឲ្យបានរូបកាយជាត់ធំមាំមួន ។ ត្រូវហាត់ប្រាណនៅទីណា ។ នៅនៅពេលណា ។ ក្នុងពេលហាតប្រាណ មិនត្រូវធ្វើរាយមាយឲ្យសោះ ។ ត្រូវខំប្រឹងប្រែងឲ្យមាំមួន ទើបបានរូបកាយនោះសមល្អ ហើយជម្ងឺរោគាក៏មិនអាចនឹងបៀតបៀនបានផង ។ ម្យ៉ាងទៀត ត្រូវហាត់ដើរក្នុង ១ ថ្ងៃឲ្យបាន ២ ម៉ោង ដេកពីព្រលុប ក្រោកពីព្រលឹម ឲ្យខ្យល់អាកាសចូលក្នុងដំណេកឲ្យបរិបូណ៌ ។

## ភាគទី២ ការសំអាតខ្លួន

### មេរៀនលេខ១

ក– នៅលើស្បែកយើងមានអ្វី ។ រន្ធនោះប្រយោជន៍យ៉ាងណាខ្លះ ។ ញើសមានជាតិហើយក្លិនដូចម្តេច ។ បើកាលណាញើសចេញមិនរួចពីក្នុងខ្លួនមកតើនឹងបណ្តាលយ៉ាងណាទៅ ។ បើបង់ឲ្យញើសចេញបានស្រួលត្រូវធ្វើដូចម្តេច ។ មនុស្សដែលខ្ជិលសំអាតខ្លួនមានរូបកាយយ៉ាងណា ។ កមរមាស់ ដំបៅងា កើតមកតែពីសេចក្តីស្មោកគ្រោក ។

១– ការជុសលាងខ្លួនប្រែណ.– នឹងទឹកទទេមិនបានគ្រប់គ្រាន់ទេ ត្រូវប្រើសាប៊ូផងទើបបានស្អាតល្អ ។ មួយថ្ងៃអ្នកត្រូវលាងសាប៊ូប៉ុន្មានដង ។ ជារឿយៗ មុនហើយនឹងក្រោយពេលបាយជាដើម ពីព្រោះអ្វីបានជាគេត្រូវលប់លាងខ្លួននឹងដៃជើងវេលាយប់មុនចូលដេក ។ (ប្រយោជន៍ឲ្យដេកបានស្រួលស្កប់ស្កល់ ) ក្រចកត្រូវកាត់ឲ្យខ្លី ។ សក់ត្រូវលាងទឹកក្តៅអ៊ុនៗ ហើយនឹងសាប៊ូ ១ អាទិត្យម្តង ។

# លោកនិតិ

ច្បាប់នេះប្រពៃណាស់ អាចឲ្យយើងដឹងរបៀបរាជការផ្សេងៗ នឹងច្បាប់ទម្លាប់ដែលមានបញ្ញត្តិដល់ពលរដ្ឋទាំងពួង ដែលត្រូវគោរពប្រតិបត្តិតាម ។ ហេតុនេះយើងត្រូវហ្វឹកហ្វឺនសិស្សអំពីច្បាប់ ឬកិច្ចអ្វីដែលងាយ តម្រូវតាមរបៀបសិក្សារាល់ៗ ពីព្រោះប្រទេសយើងសព្វថ្ងៃពុំទាន់មាន លក្ខន្តិកៈ ឲ្យច្បាស់លាស់យ៉ាងណានៅឡើយទេ ម្ល៉ោះហើយច្បាប់បញ្ញត្តិដែលមានពីមុនមក ក៏ផ្លាស់ប្តូរជាច្រើនដែរ ។ ប៉ុន្តែខាងរបៀបរាជការ យើងត្រូវប្រតិបត្តិតាម "រដ្ឋធម្មនុញ្ញ" គឺជាច្បាប់សំរាប់កម្ពុជរដ្ឋយើងសព្វថ្ងៃនេះ ។

ហេតុនេះវេលានឹងសិក្សាសិស្សអំពីវិជ្ជានេះ យើងត្រូវនិយាយពន្យល់បណ្តើរ សួរចោទសិស្សបណ្តើរ ឲ្យសិស្សយល់ហើយចាំប្រាកដ រួចសឹមសរសេរសេចក្តីសង្ខេប ដាក់ឲ្យសិស្សរៀនតាមធម្មតា ។

សំរាប់ថ្នាក់ទាំង ៤

អានទិត្យជំនួន– ប្រទេសកម្ពុជា

កម្ពុជា គឺជាផែនដីមួយកន្លែង ក្នុងសកលលោក ជាប្រទេសរបស់ខ្មែរ មានព្រះមហាក្សត្រិយ៍សោយរាជ្យ ។ របៀបរាជការក៏មានគ្រប់គ្រាន់ដូចប្រទេសដទៃដែរ គឺមានរដ្ឋសភា - ក្រុមព្រះរាជអាណាចក្រ - រដ្ឋាភិបាលនឹងតុលាការ ។

រដ្ឋសភាគឺទីប្រជុំ អ្នកតំណាងរាស្ត្រ សំរាប់ប្រឹក្សាច្បាប់ ទំនុកបំរុងឬគ្រប់គ្រងរដ្ឋ ។ ក្រុមព្រះរាជអាណាចក្រត្រូវពិនិត្យនឹងឱ្យយោបល អំពីសេចក្ដីព្រាងច្បាប់នឹងសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមរួចហើយ ។ រដ្ឋាភិបាលគឺគណៈរដ្ឋមន្ត្រីនៃព្រះមហាក្សត្រិយ៍ គឺមន្ត្រីទំនុកបំរុងប្រទេស មានចំនួនយ៉ាងច្រើនត្រឹមដប់ពីររូបរាប់បញ្ចូលទាំងរដ្ឋលេខាធិការផង ។ តុលាការគឺក្រសួងជំរះក្ដីសុំរង់ចាំងការមិនឱ្យល្មៀង ។

សួរបោទ– ប្រទេសកម្ពុជា ៗ ប្រទេសរបស់ជាតិណា ។ ព្រះមហាក្សត្រិយ៍ព្រះនាមអ្វី ។ កម្ពុជរដ្ឋសព្វថ្ងៃនឹងពីដើម ខុសគ្នាយ៉ាងណាខ្លះ ។ (មានរបៀបរាជការគ្រប់គ្រាន់ដូចប្រទេសដទៃ)។ របៀបរាជការអ្វីខ្លះដែលអ្នកស្គាល់ ។ រដ្ឋសភាសម្រាប់ធ្វើអ្វី ។ ល។

*មេរៀនសង្ខេប*– ប្រទេសកម្ពុជា ជាប្រជាជាតិមួយក្នុងសកលលោក មានព្រះមហាក្សត្រិយ៍សោយរាជ្យ ។ ឯរបៀបរាជការក៏មានគ្រប់គ្រាន់ពេញលេញដូចប្រទេសដ៏ទៃដែរ មានរដ្ឋសភា–ក្រុមព្រះរាជអាណាចក្ររដ្ឋាភិបាលនិងតុលាការ ។

*អាទិត្យក្រោយ* – អំពីភូមិនិងឃុំ

តំបន់ណាដែលមានប្រជុំផ្ទះលំនៅច្រើនហៅថាភូមិ ដីដែលគេសង់ផ្ទះនៅក៏ហៅថាភូមិដែរ គឺដីភូមិ ។ ភាពដីនៅប្រទេសនិមួយ ៗ មិនមែនទ្រង់ទ្រាយរាបស្មើដូចគ្នាទេ ទីណាខ្ពស់ ទឹកមិនលិច គេនាំគ្នាកភូមិសង់ផ្ទះនៅ ភូមិណាធំៗហើយមានផ្លូវកាត់គ្នាទៅវិញទៅមកបានដោយងាយ ភូមិនោះមានមនុស្សច្រើន ឈ្មោះភូមិ មិនមែនរាជការឲ្យឈ្មោះទេ គឺអ្នកដែលកសាងភូមិឲ្យឈ្មោះ ជួនកាលគេឲ្យឈ្មោះតាមឈ្មោះមនុស្សក៏មាន ជួនកាលឈ្មោះតាមរុក្ខជាតិដែលដុះនៅទីនោះក៏មាន ។

ភូមិរួមគ្នាពីរឬបីឡើងទៅបានជាឃុំមួយ មានមន្ត្រីម្នាក់នាយកត្រួតត្រា ហៅថាមេឃុំ ។ នៅក្រុងភ្នំពេញ គេចែកឃុំជាសង្កាត់ ៗ

ខណ្ឌគ្មានឹងផ្លូវឈ្មោះឃុំលេខ១ពីដើម គេហៅថាសង្កាត់លេខ១ ទៅវិញ មេឃុំក៏ប្រែហៅថាមេសង្កាត់វិញដែរ ។

មេឃុំមានស្មៀននឹងជំទប់ជួយធ្វើការ ទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិ ។ មេឃុំជាអាណាព្យាបាលលើឃុំ ជួយទំនុកបំរុងរាស្ត្រឲ្យបានសន្តិសុខ ។

សួរ ហេតុ.— អ្នកនៅភូមិណា ។ ពីព្រោះអ្វីបានជាគេហៅឈ្មោះភូមិអ្នកយ៉ាងដូច្នេះ ។ ភូមិអ្នកតូចឬធំ ។ មានមនុស្សនៅប្រហែលប៉ុន្មាននាក់ ។ ពីព្រោះអ្វីបានជាគេកសាងភូមិអ្នកនៅទីនោះ។ អ្នកណាដែលត្រួតត្រាលើភូមិអ្នក ។ យ៉ាងដូចម្តេចដែលហៅថាឃុំ ។ មេឃុំធ្វើអ្វីខ្លះ ។ល។

*មេរៀនសង្ខេប.—* ភូមិគឺតំបន់ដែលមានប្រជុំផ្ទះលំនៅច្រើន ភូមិណាធំទូលាយ មានផ្លូវកាត់ភ្ជាប់ទៅវិញទៅមកបានដោយងាយ ភូមិនោះមានមនុស្សនៅច្រើនជាងគេ ។

ឃុំគឺទីប្រជុំភូមិច្រើនឬតិចតាមបញ្ញត្តិរាជការរដ្ឋបាល នាទីក្នុងអំណាចមេឃុំម្នាក់ ។ មេឃុំជាអាណាព្យាបាលលើឃុំ ការពាររាស្ត្រឲ្យបានសន្តិសុខ មានស្មៀននឹងជំទប់ជួយធ្វើការ ទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិ ។

បរិច្ឆណដ្ឋាន

# មេសូត្រតមាត់

## ការរបរ

ឯការរបរគ្រប់ទាំងអស់ នេះជាអម្រិសប្រសើរក្រៃ
អាចឲ្យប្រយោជន៍យើងរាល់ថ្ងៃ ហើយមានដំឡៃលើកមុខផង ។
ដូចជាអ្នកលក់ស្បៀងអាហារ ដាក់រានក្នុងផ្សារនោះបំណង
យកផលប្រយោជន៍ពីជនផង ដែលដើរតឹកកងមកទិញដូរ ។
យកទៅអាស្រ័យកែរស្រេកឃ្លាន ប្រាក់មានគ្មានស្តាយតាយបង្គួរ
នេះហើយរបរការលក់ដូរ សម្បូណ៌សម្បត្តិទ្រព្យរាប់សែន ។

---

សព្ទពន្យល់ — ប្រសើរក្រៃ = ល្អពេក ។ — ដំឡៃលើកមុខ = លើកដំកើងឲ្យថ្កុំថ្កើង ។ — ស្បៀងអាហារ = ម្ហូបចំណី ។ — ផលប្រយោជន៍ = ប្រាក់កាស ដែលបានអំពីមុខការរបរ ។ — ជន = មនុស្ស ។ — តឹកកង = ស្ទូរសន្ធឹកមនុស្ស ។ — សម្បូណ៌សម្បត្តិទ្រព្យ = ទ្រព្យសម្បត្តិច្រើន ។ — អម្រិស = របរ, មុខការរបរ ។

## អាទិកដ្ឋាន

### អង្គសង្ខារិក

អង្គសង្ខារិកគឺប្រជុំ ផ្នែកតូចផ្នែកធំក្នុងខ្លួនយើង
ដងខ្លួនហើយនឹងក្បាល ដៃ-ជើង ត្រូវយើងឲ្យហៅអវយវៈ ។

ក្បាលមានថ្គាមច្រើនផ្តុំដោយឡែក
បែកផ្សេងពីគ្នាតាមរបរៈ
គឺថ្គាមលលាដ៍ថ្គាមមុខៈ
ជាប់នៅអត្តភាពនេះឯង ។
ថ្គាមលលាដ៍ក្បាលសំប៉ែតកោង
ប្រពោងបង្កាំគ្នារណែង
ផិតដូចដំណាប់ក្បាលអណ្តែង
សណ្ឋានទ្រវែងពងក្រពើ ។

សព្ទពន្យល់ – អដ្ឋិសង្ខលិក = គ្រោងឆ្អឹង ។ – អវយវៈ = ខ្លួនប្រាណ ។ – ដោយឡែក = ដោយបែកផ្សេង ឬដោយខ្លួនផ្សេង ។ – មុខៈ = គឺមុខមនុស្ស ដែលមាន វិសជ្ជនីយ (ៈ) ក្នុងទីនេះ ដើម្បីឲ្យត្រូវសម្ផស្សនឹងពាក្យ របរៈ ប៉ុណ្ណោះទេ ។ – អត្តភាព = ភាវៈរបស់ខ្លួន ។ – រណែង = ពាក្យសំរាប់និយាយផ្សំនឹងពាក្យ រណោង គឺពេញពាស ។ – ដំណាប់ក្បាលអណ្តែង = រណ្តៅ, រន្ធ ដែលកើតពីជាប់ សណ្ឋានដូចក្បាលត្រីអណ្តែង ។ – របរៈ = ឆ្ងាយ-ជិត-ខ្ពស់-ទាប វែង-ខ្លី ។

## មជ្ឈិមដ្ឋាន ទី ១

# សាលារៀនល្អ

សាលារៀនល្អ សាងពីឥដ្ឋ-ថ្ម កជាផ្ទះធំ ដំបូលប្រក់ក្បឿង ខ្ពង់លើជាងព្រំ ដញ្ជាំងបាំងហ៊ុម ទ្វារធំទូលាយ ។ បង្អួចលាបថ្មី ពណ៌បៃតងខ្ចី រស្មីពណ្ណរាយ សង់នៅកណ្តាល ទីទួលទូលាយ ខ្ពស់ខ្ពង់ទ្រង់ទ្រាយ ផ្ទៃដីរាបស្មើ ។ របស់មានគ្រប់ តាំងក្នុងបន្ទប់ សំរាប់ទុកប្រើ នៅក្នុងសាលា ជើងម៉ាតុឈើ ស្រឡៀវជាងធ្វើ ខាត់ភ្លឺរលោង ។ មានផែនទីគួរ រូបភាពគំនូរ បងព្យួររយោង សំពោកតាមផ្ទាំង ដញ្ជាំងព្រាតព្រោង បើសិស្សណាងោង គ្រូឈោងដោះមក ហើយគ្រូចង្អុល និយាយពន្យល់ ឲ្យសិស្សចាំយក ចាប់ពីព្រឹក្សា សីលាថ្មមក បោះសិស្សឲ្យរក បែបរៀងបានរៀន

សព្ទពន្យល់ – សាង = ធ្វើឲ្យកើតឡើង ។ – ក = តាំងផ្តើមធ្វើ ។ – ព្រំ = ប្លុកបាយអភ្ជិតកន្ទែងប្រទល់ក្បឿង ។ – បាំងហ៊ុម = បាំងព័ទ្ធជុំវិញ ។ – រស្មី = ពន្លឺចាំងព្រាក ។ – ពណ្ណរាយ = ភ្លឺល្អ ។ – រូបភាព = រូបគំនូរ ។ – ព្រឹក្សា = ឈើ។ សិលា = ថ្ម ។ – ផ្ទៃដី = ដីមួយផ្ទាំង ឬផ្ទាំងដី ។

## មជ្ឈិមដ្ឋានទី ២ – ឧត្តមដ្ឋាន

# មនុស្សជាន់ដើម

ជាតិមនុស្សជាន់ដើម និស្ស័យចិត្តថ្លើម ផ្ទុកគ្នាទីទៃ នៅដោយរូងភ្នំ ធំៗ ក្នុងព្រៃ ឥតមាន **វិន័យ** និងច្បាប់ទម្លាប់ ។ កាយអាក្រាតផ្លាំង ខ្លះបានបិទបាំង ដោយគ្រឿងមិនជាប់ ខ្លះស្លឹកឈើខ្ចប គ្រប់ធ្វើទ្រនាប់ ការឈឺសោកមិនសព្វ ទ្រាំតែគេរំខាស់ ។

សម័យឥឡូវ មនុស្សដឹងខុសត្រូវ ស្គាល់ផ្លូវល្អច្បាស់ ស្គាល់ច្បាប់ទម្លាប់ បេះរាប់អានសាស្ន បេះផ្លូវប្រែផ្លាស់ មិនខ្មាស់មុខជាតិ ។ មានវិទ្យាល័យ សិក្សាសម័យ ថ្មីនាំមារយាទ ទៅរករុងរឿង ដំកើងស្ទួយជាតិ ទើបក្លាយខ្ទួសឃ្លាត ពីការល្ងង់ខ្លៅ ។

---

សព្ទពន្យល់ – និស្ស័យ = ទម្លាប់ ។ – វិន័យ = ការដឹកនាំទៅរកផ្លូវល្អ ។ កាយអាក្រាត – មិនស្លៀកសំពត់ ។ អក្រាតផ្លាំង = ស្រាតផ្លាំង – ខ្ចប = ផ្គោបឬប៉ះ ជាការបិទដោយអន្លើ ៗ ។ – សាស្ន = កាន់សាសនាមតេទូសាស្នជាដើម ។ – វិទ្យាល័យ មន្ទីរសិក្សា ។ – រុងរឿង = ល្អប្រពៃ ។ –